ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៦ សរ

# សារាចរ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និង ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧

## ១-សេចក្តីផ្តើម

១-អនុលោមតាមមាត្រា ៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញនូវសារាចរស្តីពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧ តាមរយៈលិខិតលេខ ០០១ សហវ.ស.រ.អថ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២៦ ដោយបានកំណត់អំពីក្របខ័ណ្ឌពេលនៃការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ និងការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ ព្រមជាមួយនឹងការកំណត់ពេលសម្រាប់ដាក់ចេញនូវសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧។ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម គឺជាផែនការរយៈពេលមធ្យមកម្រិតយុទ្ធសាស្ត្រ ដែលត្រូវបានរៀបចំតាមអភិក្រមពីលើចុះក្រោម (Top Down) មានភាពប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមករវាងក្របខ័ណ្ឌទាំងពីរនេះដែលផ្តល់ជាទស្សនវិស័យ និងតម្រង់ទិសការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការគ្រប់គ្រងថវិកាជាតិ ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់រយៈពេលមធ្យម។

២-ផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ ឬហៅខ្លីថា «ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩» ដែលទទួលបានការអនុម័តរបស់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២៦ (បានផ្សព្វផ្សាយជាសាធារណៈលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ), ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ ឬហៅខ្លីថា «ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៧-២០២៩» ត្រូវបានរៀបចំជាឯកសារមួយបន្ថែមទៀត ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីលម្អិតក្របខ័ណ្ឌចំណាយថវិការយៈពេលមធ្យមពីកម្រិតវិស័យ ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុឆ្នាំ ២០២៧-២០២៩ ទៅដល់កម្រិតក្រសួង ស្ថាប័ន ដើម្បីផ្តល់ជាទស្សនវិស័យអំពីលទ្ធភាពថវិការយៈពេលមធ្យម ទាំងផ្នែកចំណាយចរន្ត និងផ្នែកចំណាយមូលធន តាមរយៈការដាក់ចេញនូវពិតានចំណាយគោលសម្រាប់រយៈពេល ៣ ឆ្នាំ (២០២៧-២០២៩) ជូនដល់ក្រសួង ស្ថាប័ន ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់អនុវត្តការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលពិតានចំណាយគោលនេះ គឺជាផ្នែកមួយដ៏សំខាន់នៃការដាក់ចេញនូវ



៩

សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ២០២៧ ដើម្បីគ្រប់ក្រសួង ស្ថាប័ន អាចប៉ាន់ប្រមាណបានអំពីលទ្ធភាពថវិកាសម្រាប់ជាមូលដ្ឋានក្នុងការលើកគម្រោងថវិកា។ លើសពីនេះ, ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៧-២០២៩ ក៏មានសារៈសំខាន់យ៉ាងខ្លាំងជួយដល់ក្រសួង ស្ថាប័ន ក្នុងការពង្រឹងការធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ទាំងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស និងទាំងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។

៣-ដូចនេះ, ផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៧-២០២៩ និងក្របខ័ណ្ឌថវិកាឆ្នាំ ២០២៧-២០២៩, **សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧** ត្រូវបានដាក់ចេញដើម្បីផ្តល់មគ្គុទេសក៍បច្ចេកទេសគន្លឹះៗ និងការណែនាំផ្នែកបច្ចេកទេសដល់គ្រប់ក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់ការរៀបចំថវិកាពាក់ព័ន្ធនឹងមុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា (៣ ឆ្នាំរំកិល) ឆ្នាំ ២០២៧-២០២៩ និង លើកគម្រោងថវិកាឆ្នាំ ២០២៧។

ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៧-២០២៩ និងក្របខ័ណ្ឌថវិកាឆ្នាំ ២០២៧-២០២៩ បានកំណត់នូវក្របខ័ណ្ឌគោលនយោបាយ និងសូចនាករសំខាន់ៗ ដូចខាងក្រោម៖

## ២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៤-បើទោះបីជាស្ថានភាពនៃសេដ្ឋកិច្ចសកលបន្តស្ថិតក្នុងភាពចល័ត និងភាពមិនប្រាកដប្រជាខ្ពស់យ៉ាងណាក្តី ពិសេសដោយសារការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃរបបពាណិជ្ជកម្មសកល តួយ៉ាងតាមរយៈការដាក់ចេញនូវពន្ធគយបដិការក្នុងខែ មេសា ឆ្នាំ ២០២៥ ជាដើម ក៏កំណើនសេដ្ឋកិច្ចសកល នៅបន្តរក្សាបានចលនការល្អពុំអាក្រក់ខ្លាំងដូចការរំពឹងទុកក្រោយពីការប្រកាសដាក់ចេញនូវពន្ធគយបដិការភ្លាមៗនោះទេ។ ផ្អែកតាមរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចសកល របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបោះផ្សាយក្នុងខែ មេសា ឆ្នាំ ២០២៦, សេដ្ឋកិច្ចសកល ក្នុងឆ្នាំ ២០២៥ ត្រូវបានវាយតម្លៃថាសម្រេចបានកំណើនក្នុងអត្រា ៣,៤% ដែលចូលរួមគាំទ្រដោយកត្តាសំខាន់ៗ ទាំងបី ជាអាទិ៍ ទី១)- ការពន្លឿនការនាំចេញ (Front-loading) នៅក្នុងឆមាសទី ១ ឆ្នាំ ២០២៥, ទី២)- ការបន្តនិន្នាការល្អនៃការវិនិយោគលើវិស័យបច្ចេកវិទ្យា ពិសេសបញ្ញាសិប្បនិម្មិត (AI) និងថាមពលស្អាត ពីបណ្តាប្រទេសអភិវឌ្ឍន៍ តួយ៉ាងសហរដ្ឋអាម៉េរិក, និង ទី៣)- ការបន្តបន្ធូរបន្ថយជាសន្សឹមៗនៃគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ គួបផ្សំនឹងការអនុវត្តគោលនយោបាយវិត្តារកម្មថវិកា ដើម្បីគាំពារកំណើនសេដ្ឋកិច្ចរបស់បណ្តាប្រទេសមួយចំនួនតួយ៉ាង ចិន, កូរ៉េខាងត្បូង និងអាល្លឺម៉ង់ ជាដើម។ ការវាយតម្លៃចុងក្រោយបានបង្ហាញថា សន្ទុះកំណើនសេដ្ឋកិច្ចសកល ជារួមក្នុងឆ្នាំ ២០២៥ បានខិតទៅរកល្បឿននៃកំណើនដូចការវាយតម្លៃក្នុងបរិការណ៍មុនការប្រកាសដាក់ឱ្យអនុវត្តពន្ធគយបដិការ ពោលគឺការវាយតម្លៃក្នុងខែ មករា ឆ្នាំ ២០២៥ កន្លងទៅ។

សម្រាប់ឆ្នាំ ២០២៦, កំណើនសេដ្ឋកិច្ចសកល ត្រូវបានប៉ាន់ស្មានថាមានកំណើនថមថយ មកត្រឹមអត្រា ៣,១% ទាបជាងការព្យាករដើមឆ្នាំ ដោយសារកម្មវិបាកនៃសង្គ្រាមក្នុងតំបន់មជ្ឈិមបូព៌ា ដែលបណ្តាលឱ្យមានការកើនឡើងយ៉ាងគំហុក នៃថ្លៃប្រេងឥន្ធនៈអន្តរជាតិ មកលើសកម្មភាពសេដ្ឋកិច្ច ខណៈមានការបន្ទចំបង្អាក់

ដល់រំហូរពាណិជ្ជកម្ម និងទំនុកចិត្តវិនិយោគជារួម។ ទោះជាយ៉ាងនេះក្តី, ផលរំខាននៃសង្គ្រាមនេះ មកលើកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០២៦ គឺមានភាពខុសៗគ្នាទៅតាមបណ្តាប្រទេសនីមួយៗ។ **ក្នុងឆ្នាំ ២០២៧ និងរយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៨-២០២៩)** កំណើនសេដ្ឋកិច្ចសកល ជារួមនៅបន្តរក្សាបានស្ថិរភាពកំណើនក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ប្រមាណ ៣,២% ក្រោមការរំពឹងទុកការត្រលប់ទៅរកប្រក្រតីភាពវិញនៃច្រវាក់ផ្គត់ផ្គង់សកល, ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ប្រេងឥន្ធនៈគួបផ្សំនឹងនិន្នាការនៃការបន្តវិនិយោគលើបញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាកម្រិតខ្ពស់ដទៃទៀត ដើម្បីបង្កើនផលិតភាព គួបផ្សំនឹងការបន្តជំរុញការវិនិយោគលើថាមពលបៃតង ក្នុងគោលដៅលើកកម្ពស់ការអភិវឌ្ឍប្រកបដោយ ចីរភាពសកល។

**៥-ក្នុងឆ្នាំ ២០២៥ កន្លងទៅ**, សេដ្ឋកិច្ចកម្ពុជាបានទទួលរងព្យុះកំបុតត្បូង (headwind) ចំនួន ២ ចម្បងៗ នោះគឺការដាក់ឱ្យអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក និងភាពតានតឹងនៃបញ្ហាព្រំដែនកម្ពុជា-ថៃ រហូតឈានដល់ការប៉ះទង្គិចប្រដាប់អាវុធចំនួន ២ លើក។ ជាកុសលសម្រាប់កម្ពុជា, ការអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក ពុំបានរំលេចនូវបច្ច័យអវិជ្ជមានណាមួយធំដុំលើសកម្មភាពសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៥ នោះទេ, ដោយផ្ទុយទៅវិញ បានជំរុញការនាំចេញរបស់កម្ពុជាទៅទីផ្សារសហរដ្ឋអាម៉េរិក ដោយសារការពន្លឿនការនាំចេញ (Front-loading) មុនអត្រាផ្លូវការចូលជាធរមាន ពេលក្នុងឆមាសទី ១ ឆ្នាំ ២០២៥។ ក្រោយអត្រាពន្ធគយបដិការ ១៩% ដែលជាកម្រិតប្រហាក់ប្រហែលទៅនឹងបណ្តាប្រទេសក្នុងតំបន់ ចូលជាធរមានចាប់តាំងពីអំឡុងខែ សីហា ឆ្នាំ ២០២៥ កន្លងមក ក៏ពុំបានបន្ទប់បង្អាក់ដល់ការនាំចេញកម្ពុជាទៅទីផ្សារសហរដ្ឋអាម៉េរិកនោះដែរ ពោលទាំងផលិតផលកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលទីផ្សារផ្សេងទៀត តួយ៉ាង សហភាពអឺរ៉ុប ក៏នៅតែមានស្ថានភាពល្អប្រសើរ។ យ៉ាងណាមិញ, ការបិទខ្ទប់ព្រំដែនគោកកម្ពុជា-ថៃ ដោយឯកតោភាគីរបស់ថៃ និងភាពតានតឹងជុំវិញបញ្ហាព្រំដែនបានបង្កជាបច្ច័យអវិជ្ជមានគួរឱ្យកត់សម្គាល់ដល់សកម្មភាពសេដ្ឋកិច្ចកម្ពុជា ជាអាទិ៍ : សកម្មភាពផលិតកម្មថៃបូកមួយ (Thailand+1), សកម្មភាពទេសចរណ៍ដែលពឹងផ្អែកច្រកព្រំដែនកម្ពុជា-ថៃ, ការនាំចេញផលិតផលកសិកម្ម និងផ្ទៃដីដាំដុះ រួមមាន : ពោតក្រហម និងដំឡូងមី, រំហូរនៃប្រាក់បង្វែរឯកជន ដោយសារការវិលត្រលប់មកវិញនៃទេសន្តរប្រវេសន៍កម្ពុជា, និងបច្ច័យមកលើសកម្មភាពដឹកជញ្ជូន និងវិស័យហិរញ្ញវត្ថុជាដើម។ ទោះយ៉ាងនេះក្តី, កម្ពុជា មានការលេចចេញនូវនិន្នាការថ្មីៗគួរឱ្យកត់សម្គាល់មួយចំនួន រួមមាន : ការងាកមកគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុក និងការបង្កើនសមត្ថភាព និងកម្លាំងផលិតកម្មក្នុងស្រុក, ការបង្វែរទិសដៅដឹកជញ្ជូន (Re-routing) និងការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូន, និងការធ្វើពិពិធកម្ម នៃច្រវាក់តម្លៃពីទីផ្សារថៃ ពោលទាំងក្នុងវិស័យផលិតកម្ម និងសេវាកម្ម ពិសេសទេសចរណ៍។ ជារួម, បញ្ហាព្រំដែនកម្ពុជា-ថៃនេះ នឹងផ្តល់កម្មវិបាកទាំងវិជ្ជមាន និងអវិជ្ជមានដល់ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៦ និងក្នុងរយៈពេលខ្លី និងមធ្យម ខាងមុខ។

**សម្រាប់ឆ្នាំ ២០២៦**, សេដ្ឋកិច្ចកម្ពុជា ត្រូវបានវាយតម្លៃនឹងសម្រេចបានកំណើនក្នុងអត្រា ៤,២% ប៉ុណ្ណោះ ដែលថមថយពីអត្រា ៥,៣% ឆ្នាំ ២០២៥ និងពីអត្រា ៥,០% ពីការរំពឹងទុកក្នុងច្បាប់ថវិកាកន្លងទៅ ដោយសារកម្មវិបាកផ្ទួនៗគ្នាជាអវិជ្ជមានពីបញ្ហា ៣ ធំៗ នោះគឺ : ១)- ការកើនឡើងថ្លៃប្រេងឥន្ធនៈ ពិសេសមកលើវិស័យដែលពឹងផ្អែកលើប្រេងជាកត្តាផលិតកម្ម តួយ៉ាង កសិកម្ម, ដឹកជញ្ជូន, និងទេសចរណ៍ ជាដើម គួបផ្សំនឹងការកើនឡើងនៃសម្ពាធអតិផរណា ដែលអាចបន្ទប់បង្អាក់ដល់សកម្មភាពចាយ និងប្រើប្រាស់ជារួម, ២)- កម្មវិបាក និងឥទ្ធិពលសាយភាយពីបញ្ហាព្រំដែនកម្ពុជា-ថៃ ពិសេសលើប្រាក់បង្វែរឯកជន, ទេសចរណ៍ ដែលពឹងផ្អែកច្រក

ព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងការនាំចេញកសិផល ជាដើម និង ៣)- ផលប៉ះពាល់ក្នុងរយៈពេលខ្លី នៃការបង្រ្កាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាមកលើសេដ្ឋកិច្ចពណ៌ស ពិសេសវិស័យសំណង់-អចលនទ្រព្យ និងការ-ប្រើប្រាស់ក្នុងស្រុក ដោយសារការបាត់បង់ចំណូលពីសកម្មភាពនេះ។

៦-កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា ស្ថិតក្នុងអត្រា ៥,០% ក្នុងឆ្នាំ ២០២៧ និង ជាមធ្យម ៥,៥% សម្រាប់ឆ្នាំ ២០២៨-២០២៩, ដែលក្នុងនោះ៖ ១)- **វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថា មានកំណើនក្នុងអត្រា ៧,៣% ក្នុងឆ្នាំ ២០២៧ និងក្នុងរង្វង់អត្រា ៧,៦% សម្រាប់រយៈពេលមធ្យម ២០២៨-២០២៩ ក្នុងនោះ, អនុវិស័យកាត់ដេរ នៅបន្តមានចលនការកំណើន ដែលបន្តគាំទ្រដោយការបន្តនិន្នាការវិជ្ជមាន និងការធ្វើពិពិធកម្មនៃការនាំចេញផលិតផលកាត់ដេរ ពោលទាំងទៅលើផលិតផល និងទីផ្សារ។ ២)- **វិស័យសេវាកម្ម** ត្រូវបានព្យាករថា នឹងមានកំណើនក្នុងអត្រាប្រមាណ ៣,៨% ក្នុងឆ្នាំ ២០២៧ និងប្រមាណ ៤,៥% សម្រាប់រយៈពេលមធ្យម ២០២៨-២០២៩ ដោយសារការបន្តងើបនៃវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ និងសេវាកម្មទេសចរណ៍គាំទ្រផ្សេងទៀត ខណៈដែលវិស័យអចលនទ្រព្យ ដូចគ្នាទៅនឹងអនុវិស័យសំណង់ដែរ ក៏ងើបឡើងវិញក្នុងល្បឿនយឺត។ ៣)- **វិស័យកសិកម្ម** ត្រូវបានព្យាករថា នឹងមានកំណើន ១,២% ក្នុងឆ្នាំ ២០២៧ និង ១,៣% សម្រាប់ឆ្នាំ ២០២៨-២០២៩ ដោយសារការរំពឹងទុកកំណើនប្រសើរនៃអនុវិស័យដំណាំ និងការបន្តរក្សាស្ថិរភាពកំណើននៃអនុវិស័យនេសាទ ស្របពេលដែលអនុវិស័យចិញ្ចឹមសត្វ នៅបន្តរក្សាស្ថិរភាពកំណើន។

៧-ជារួម, សេដ្ឋកិច្ចកម្ពុជា ដែលមានទំហំតូចហើយបើកចំហ និងមានការផ្សារភ្ជាប់កាន់តែខ្លាំងជាមួយនឹងច្រវាក់ផលិតកម្មក្នុងតំបន់ និងពិភពលោក, សម្រាប់រយៈពេលមធ្យមខាងមុខ ជាពិសេសសម្រាប់ឆ្នាំ ២០២៧, បាន និងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាដែលបណ្តាលមកពីកត្តាខាងក្រៅ រួមមាន៖ ១)- ការផ្ទុះសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា ដែលបង្កឱ្យថ្លៃប្រេងឥន្ធនៈកើនយ៉ាងគំហុក, ២)- ការអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក, ៣)- ការថមថយសន្ទុះសេដ្ឋកិច្ចសកល ជាពិសេសប្រទេសជាដៃគូពាណិជ្ជកម្មជាមួយកម្ពុជា និង ៤)- បញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ។ ទន្ទឹមនេះ, កម្ពុជាក៏នៅតែបន្តប្រឈមនឹងបញ្ហាក្នុងប្រទេស រួមមាន៖ ១)- សន្ទុះកំណើនយឺតក្នុងវិស័យមួយចំនួន ជាអាទិ៍ សំណង់, អចលនទ្រព្យ និងទេសចរណ៍, ២)- ការនាំចេញនៅមានលក្ខណៈប្រមូលផ្តុំខ្លាំង តែទៅកាន់ទីផ្សារមួយចំនួន, ៣)- បញ្ហាបំណុលឯកជន ដែលស្ថិតក្នុងកម្រិតខ្ពស់ និងការបន្តកើនឡើងនៃឥណទានមិនដំណើរការ (NPL) និង ៤)- ការកៀរគរចំណូលបន្តមានកំណើនទាប និងការថមថយនៃហិរញ្ញប្បទានក្រៅប្រទេស។ ជាមួយគ្នានេះ, ទន្ទឹមនឹងការកើននៃហានិភ័យខាងក្រៅ និងខាងក្នុង, កម្ពុជាក៏នៅតែបន្តប្រឈមបញ្ហាជារចនាសម្ព័ន្ធផ្ទៃក្នុងមួយចំនួន ដែលទាមទារការពង្រឹងការដ្ឋានកែទម្រង់ស៊ីជម្រៅដូចជា៖ ១)- ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច, ២)- ថ្លៃដើមធុរកិច្ចនៅមិនទាន់មានភាពប្រកួតប្រជែង, ៣)- ភាពមានកម្រិតនៃគុណភាពនៃកម្លាំងពលកម្ម ដែលមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និង ៤)- កង្វះខាតនូវឧស្សាហកម្មដើមខ្សែ (Upstream industries) និងឧស្សាហកម្មប្រតិគមន៍ គួបផ្សំនឹងភាពមានកម្រិតនៃការថ្កក់ភ្ជាប់ឧស្សាហកម្មទាំងនោះ ទៅនឹងខ្សែច្រវាក់ផលិតកម្មក្នុងស្រុក។

៨-ក្នុងបរិការណ៍នេះ, កិច្ចការកែទម្រង់ជារចនាសម្ព័ន្ធ និងការរៀបចំយន្តការអនុវត្តឱ្យបានច្បាស់លាស់ជាអាទិភាពដ៏ចាំបាច់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុកឱ្យកាន់តែមានសន្ទុះកាន់តែខ្លាំងក្លា និងដើម្បីបញ្ចៀសនូវផលប៉ះពាល់នៃហានិភ័យនានាទាំងកម្រិតសកលនិងតំបន់។ ដូចនេះ, ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោ-បាយ, រាជរដ្ឋាភិបាលនៅតែបន្តប្រកាន់ខ្ជាប់នូវអភិក្រមចំនួន ២ នោះគឺ៖ ១)-**វិធានការឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ចំពោះមុខ និងក្នុងរយៈពេលខ្លី** ដោយផ្តោតលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ការរក្សាលំនឹង

ជីវភាព និងនិរន្តរភាពសកម្មភាពសង្គម-សេដ្ឋកិច្ច និង ២)- **វិធានការគោលនយោបាយរយៈពេលមធ្យម និងវែងខាងមុខ** ដោយផ្តោតលើការបន្តដោះស្រាយជារចនាសម្ព័ន្ធក្នុងការជំរុញពិពិធកម្មសេដ្ឋកិច្ច, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការកសាងភាពធន់សម្រាប់សង្គម-សេដ្ឋកិច្ច ដើម្បីត្រៀមលក្ខណៈឆ្លើយតបទៅនឹងវិបត្តិ។ ស្របតាមអភិក្រមខាងលើនេះ, រាជរដ្ឋាភិបាលបានដាក់ចេញវិធានការគោលនយោបាយ ដូចមានខ្លឹមសារពិស្តារនៅក្នុងឯកសារក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៧-២០២៩ ដែលរួមមាន៖ ១)- វិធានការគោលនយោបាយដោះស្រាយបញ្ហាចំពោះមុខ, ២)- វិធានការគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, ៣)- វិធានការគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុ, និង ៤)- វិធានការគោលនយោបាយដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ។

៩-ក្នុងរយៈពេលមធ្យមខាងមុខ (២០២៧-២០២៩), **អត្រាអតិផរណា** ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ២,៥% ស្របគ្នាទៅនឹងនិន្នាការរឹងមាំនៃសកម្មភាពសេដ្ឋកិច្ច ក្នុងខណៈដែលថ្លៃទំនិញអន្តរជាតិនៅបន្តមានប្រក្រតីភាព។ ជាមួយគ្នានេះ, **អត្រាប្តូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាមេរិក)** រំពឹងថារក្សាបានក្នុងរង្វង់ជាមធ្យម ៤ ០៥០ រៀល/ដុល្លារអាមេរិក ក្រោមការរំពឹងទុកនៃការរក្សាបានស្ថិរភាពនៃរូបិយប័ណ្ណដុល្លារអាមេរិក គួបផ្សំនឹងការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុគាំទ្រកំណើន និងធានាស្ថិរភាពថ្លៃ។

១០-ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ប្រមាណ -៦,៩% នៃ ផ.ស.ស. ដោយសារការរំពឹងទុកការរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ក៏មានការកើនឡើងជាបន្តបន្ទាប់, ខណៈប្រាក់បង្វែរឯកជនរំពឹងថានឹងកើនឡើងវិញជាសន្សឹមៗ ប៉ុន្តែរំពឹងថានឹងមិនអាចវិលត្រលប់ទៅរកកម្រិតមុនបញ្ហាព្រំដែនកម្ពុជា-ថៃវិញឡើយ។ ក្នុងរយៈពេលមធ្យមខាងមុខ ទំហំពាណិជ្ជកម្មកម្ពុជា នឹងមាននិន្នាការកើនឡើងជាបន្តបន្ទាប់ ស្របពេលដែលការនាំចេញនឹងកាន់តែមានពិពិធភាព និងតម្លៃបន្ថែមខ្ពស់ជាងមុន តួយ៉ាងការបន្តរីកធំនៃផលិតកម្ម និងការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ពិសេសលើប្រភេទឧស្សាហកម្មសក្តានុពល ជាអាទិ៍ គ្រឿងបង្គុំអេឡិចត្រូនិក, ខ្សែចម្លងអគ្គិសនី, គ្រឿងបន្លាស់រថយន្ត, សំបកកង់រថយន្ត និងគ្រឿងសង្ហារិម ជាដើម។ ទន្ទឹមនេះ, ការនាំចូលក៏បន្តនិន្នាការកើនឡើងផងដែរ ដែលគាំទ្រដោយការនាំចូលវត្ថុធាតុដើមសម្រាប់ផលិតកម្មក្នុងស្រុក និងទំនិញប្រើប្រាស់ផ្សេងទៀត សំដៅបំពេញបន្ថែមនូវតម្រូវការក្នុងស្រុក។ វំហូរវិនិយោគផ្ទាល់ពីបរទេស ត្រូវបានព្យាករថានឹងបន្តកើនឡើងជាលំដាប់ក្នុងរង្វង់ប្រមាណ ១១,០% នៃ ផ.ស.ស. ពិសេសក្នុងវិស័យកសិ-ឧស្សាហកម្ម និងឧស្សាហកម្ម ដែលជាបច្ច័យពីការពង្រឹងការអនុវត្តច្បាប់ និងកម្មវិធីជំរុញវិនិយោគ គួបផ្សំនឹងការខិតខំប្រឹងប្រែងការបន្តកែលម្អបរិយាកាសធុរកិច្ច និងកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការដាក់ឱ្យអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា»** និង **«កម្មវិធីជំរុញការកែលម្អបរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជា ឆ្នាំ ២០២៥-២០២៨»**។ ផ្អែកលើមូលដ្ឋាននេះ, ទុនបម្រុងអន្តរជាតិ ត្រូវបានព្យាករថានឹងបន្តរក្សាបាននិន្នាការរឹងមាំ ដែលមានទំហំសមាមាត្រទៅនឹងការនាំចូល ប្រមាណ ៧,៩ ខែ ជាមធ្យមប្រចាំឆ្នាំ។

### ៣-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

១១-ផ្អែកលើការវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថានភាពហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៦ ព្រមជាមួយនឹងការព្យាករសម្រាប់ឆ្នាំ ២០២៧-២០២៩, គោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលមធ្យម (២០២៧-២០២៩) ត្រូវបានរៀបចំឡើង ដោយប្រកាន់យក «ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

អព្យាក្រឹត (Neutral Fiscal Stance)» ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម បន្តរក្សាស្ថិរភាពសេដ្ឋកិច្ច និងតុល្យភាពថវិកា ដោយពុំប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល។ ការកំណត់យកជំហរអព្យាក្រឹត នេះ មានភាពសមស្របទៅនឹងបរិការណ៍មិនប្រាកដប្រជាខ្ពស់នៃសេដ្ឋកិច្ចសកល ខណៈប្រភពហិរញ្ញប្បទានក្រៅប្រទេសត្រូវបានរំពឹងទុកថានឹងថមថយ ដែលតម្រូវឱ្យចំណាយសាធារណៈ ត្រូវបង្កើនត្រឹមកម្រិតដែលលទ្ធភាពធនធានថវិកាអាចទ្រទ្រង់បាន ដើម្បីរក្សាភាពឆ្លើយតបបានទៅនឹងបរិការណ៍ដែលមិនទាន់អាចប្រមើលឃើញ ដោយចៀសវាងនូវការគ្រោងចំណាយខ្ពស់ជាងលទ្ធភាពជាក់ស្តែងនៃចំណូល និងការបង្កើនហិរញ្ញប្បទានបន្ថែមដោយគំហុក។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តផ្តោតជាសំខាន់លើការបន្តពង្រឹងសក្តិសិទ្ធិភាពថវិកា, ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ, តាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយក្នុងនោះក្របខ័ណ្ឌចំណាយសាធារណៈនឹងត្រូវរៀបចំឡើង ដើម្បីតម្រង់ទិសធនធានទៅកាន់មុខសញ្ញាដែលជាអាទិភាពសំខាន់ៗចំពោះមុខ, ជាពិសេសការការពារអធិបតេយ្យភាពនិងបូរណភាពទឹកដី, ការរក្សាលំនឹងជីវភាពប្រជាជន, ការលើកកម្ពស់សមធម៌សង្គម, ការបន្តទ្រទ្រង់ដំណើរការនៃកិច្ចអភិវឌ្ឍសង្គម ព្រមទាំងការធានានិរន្តរភាពប្រតិបត្តិការការងាររបស់រាជរដ្ឋាភិបាល ស្របតាមទិសដៅជាយុទ្ធសាស្ត្រដែលបានដាក់ចេញនៅក្នុង «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១» របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា។

ដូចនេះ, ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, ការជំរុញអនុវត្តឱ្យសម្រេចបានជោគជ័យនូវ «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១» គឺជាអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមជាមួយការជំរុញអនុវត្ត «កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា» និង «កម្មវិធីជំរុញការកែលម្អបរិយាកាសសម្រាប់ធុរកិច្ច និងការវិនិយោគនៅកម្ពុជាឆ្នាំ ២០២៥-២០២៨» សំដៅរួមចំណែកដោះស្រាយបញ្ហាជារចនាសម្ព័ន្ធសំខាន់ៗ ឱ្យកាន់តែចំទិសដៅ និងប្រសិទ្ធភាពស្របតាមបរិការណ៍សង្គម-សេដ្ឋកិច្ចកម្ពុជា, តំបន់ និងសកល ដែលកំពុងវិវត្តយ៉ាងឆាប់រហ័ស និងពិបាកប៉ាន់ស្មាន។ ក្នុងន័យនេះ, គោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៧-២០២៩ បានកំណត់អាទិភាពសំខាន់ៗ ដូចខាងក្រោម៖

១). **ការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងធានាស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច៖** រាជរដ្ឋាភិបាល នឹងបន្តផ្តល់អាទិភាពដល់កិច្ចការការពារអធិបតេយ្យជាតិនិងបូរណភាពទឹកដី, ការការពារសន្តិភាព និងស្ថិរភាពនយោបាយ ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, សមិទ្ធផលសង្គម និងជំរុញការដោះស្រាយបញ្ហាគ្រោះអាសន្ននានា ក្នុងសង្គម។

២). **ការដោះស្រាយលំនឹងជីវភាពប្រជាជន៖** រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់លើការធានាសន្តិសុខស្បៀង, ការគាំពារ និងការបង្កើតការងារជូនប្រជាជន ជាពិសេសពលករទេសន្តរប្រវេសន៍ត្រលប់ពីថៃ ព្រមទាំងវិធានការគាំពារសង្គម សម្រាប់គ្រួសារភៀសសឹក។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល នឹងបន្តគាំទ្រពលរដ្ឋ អាជីវករខ្នាតតូច និងកសិករ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលសេដ្ឋកិច្ច និងវិបត្តិនានា សំដៅបង្កើនប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃប្រព័ន្ធគាំពារសង្គម និងការផ្តល់សេវាសង្គមចាំបាច់នានា។

៣). **ការជំរុញពិពិធកម្មសេដ្ឋកិច្ច និងអភិវឌ្ឍប្រភពថ្មីនៃកំណើន៖** រាជរដ្ឋាភិបាល នឹងបន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងអភិវឌ្ឍប្រភពថ្មីនៃកំណើន ដោយផ្តោតលើការពង្រឹងមូលដ្ឋានគាំទ្រកំណើនប្រកបដោយចីរភាព តាមរយៈការជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទ, ការអភិវឌ្ឍ

ខ្សែច្រវាក់ផលិតកម្មក្នុងស្រុក, និងការលើកកម្ពស់ការកែច្នៃ សម្រាប់ជំនួសការនាំចូល និងជំរុញការនាំចេញ ដើម្បីបង្កើនតម្លៃបន្ថែម និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច ស្របតាមអាទិភាពគោលនយោបាយ ដែលបានដាក់ចេញ។

៤). **ការពង្រឹងបរិយាកាសធុរកិច្ច និងការលើកកម្ពស់វិស័យឯកជន៖** រាជរដ្ឋាភិបាល នឹងបន្តកែលម្អបរិយាកាសធុរកិច្ច និងជំរុញការអភិវឌ្ឍវិស័យឯកជន តាមរយៈការអនុវត្តយន្តការហិរញ្ញប្បទានដែលមានលក្ខខណ្ឌអំណោយផល សំដៅគាំទ្រការពង្រីកអាជីវកម្ម និងបង្កើនផលិតភាព សម្រាប់ទាក់ទាញវិនិយោគដែលមានគុណភាពខ្ពស់។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល, ម្ខាង នឹងបន្តពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីធានាបរិយាកាសប្រកួតប្រជែង ប្រកបដោយតម្លាភាព ស្មើភាព និងយុត្តិធម៌, និងម្ខាងទៀត លើកកម្ពស់កិត្យានុភាព និងភាពជឿជាក់របស់កម្ពុជា តាមរយៈការពង្រឹងយន្តការទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលអាចប៉ះពាល់ដល់ទំនុកចិត្តវិនិយោគិន និងសុវត្ថិភាពនៃប្រតិបត្តិការធុរកិច្ច។

៥). **ការអភិវឌ្ឍមូលធនមនុស្ស និងសង្គម៖** រាជរដ្ឋាភិបាល នឹងបន្តផ្តោតលើការអភិវឌ្ឍមូលធនមនុស្ស និងសង្គម តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីគាំទ្រផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងភាពធន់។ ទន្ទឹមនេះ រាជរដ្ឋាភិបាល នឹងបន្តលើកកម្ពស់ភាពជាពលរដ្ឋក្នុងសង្គម វប្បធម៌ និងសុខុមាលភាពប្រជាជន ព្រមទាំងបន្តជំរុញការលើកកម្ពស់សុខុមាលភាពសង្គម តាមរយៈការពង្រឹងប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមចាំបាច់។

៦). **ការជំរុញបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍបៃតង៖** រាជរដ្ឋាភិបាល នឹងបន្តជំរុញបរិវត្តកម្មឌីជីថល និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ លើកកម្ពស់ផលិតភាព សំដៅកសាងរាជរដ្ឋាភិបាល និងពលរដ្ឋឌីជីថល ប្រកបដោយចីរភាព និងភាពធន់ ព្រមទាំងការលើកកម្ពស់ការអភិវឌ្ឍបៃតង ដើម្បីចូលរួមចំណែកដល់ការសម្រេចបាននូវអព្យាក្រឹតកាបូន។

៧). **ការពង្រឹងអភិបាលកិច្ច និងស្ថាប័ន៖** រាជរដ្ឋាភិបាល នឹងបន្តពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពស្ថាប័ន តាមរយៈការអនុវត្តកម្មវិធីកែទម្រង់មុតស្រួច រួមមាន កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីពង្រឹងតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ សំដៅគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

## ៣.១-ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩

១២-ផ្អែកតាមក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ និងអាទិភាពនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលបានកំណត់ខាងលើ, **ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩** ត្រូវបានដាក់ចេញដោយរក្សាក្របខ័ណ្ឌតុល្យភាព ដូចខាងក្រោម៖

## ក្របខ័ណ្ឌតុល្យភាពថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩

| ភាគរយនៃ ផ.ស.ស. | 2026 ច្ប. | 2026 កែ. | 2027ព្យ. | 2028 ព្យ. | 2029 ព្យ. |
|---|---|---|---|---|---|
| **ចំណូលសរុបថវិការដ្ឋ** | **14.89%** | **15.25%** | **15.24%** | **15.16%** | **15.16%** |
| ចំណូលចរន្តថវិការដ្ឋ | 14.37% | 14.73% | 14.76% | 14.70% | 14.68% |
| **ចំណាយសរុបថវិការដ្ឋ** | **18.60%** | **18.60%** | **17.03%** | **16.69%** | **16.43%** |
| ចំណាយចរន្តថវិការដ្ឋ | 12.42% | 12.42% | 12.41% | 12.14% | 11.85% |
| ចំណាយមូលធនថវិការដ្ឋ | 6.18% | 6.18% | 4.62% | 4.54% | 4.58% |
| **អតិរេកចរន្ត** | **1.95%** | **2.31%** | **2.36%** | **2.55%** | **2.83%** |
| **សមតុល្យថវិកា** | **-3.71%** | **-3.36%** | **-1.79%** | **-1.53%** | **-1.26%** |
| ***តម្រូវការហិរញ្ញប្បទាន*** | ***5.13%*** | ***4.78%*** | ***3.83%*** | ***3.36%*** | ***3.26%*** |
| *ឱនភាពថវិកា* | 3.71% | 3.36% | 1.79% | 1.53% | 1.26% |
| *ការខូចខាតការខ្ចី* | 1.21% | 1.21% | 1.57% | 1.36% | 1.53% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0.20% | 0.21% | 0.47% | 0.47% | 0.47% |
| ***ប្រភពហិរញ្ញប្បទាន*** | ***5.13%*** | ***4.78%*** | ***3.83%*** | ***3.36%*** | ***3.26%*** |
| *ហិរញ្ញប្បទានក្រៅប្រទេស* | 2.97% | 2.97% | 2.55% | 2.41% | 2.35% |
| *មូលនិធិទ្រទ្រង់ថវិកា* | 0.99% | 0.99% | 0.46% | 0.16% | 0.15% |
| *ការបោះផ្សាយមូលបត្ររដ្ឋ* | 0.96% | 0.96% | 0.34% | 0.32% | 0.30% |
| *ប្រាក់បញ្ញើរាជរដ្ឋាភិបាល* | 0.00% | -0.33% | 0.00% | 0.00% | 0.00% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0.20% | 0.20% | 0.47% | 0.47% | 0.47% |

ជារួម, ក្របខ័ណ្ឌចំណាយសម្រាប់ឆ្នាំ ២០២៧-២០២៩ ត្រូវបានគ្រោងឡើងស្របតាមជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញដោយធានាតុល្យភាពនៃចំណូលនិងចំណាយ និងពុំមានការប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ, ការគ្រោងចំណាយសាធារណៈសម្រាប់រយៈពេលមធ្យម ត្រូវបានរៀបចំក្នុងស្មារតីប្រុងប្រយ័ត្ន និងបុរេសកម្មខ្ពស់ ដោយប្រកាន់គោលការណ៍គោរពម៉ឺងម៉ាត់វិន័យថវិកា និងពង្រឹងសក្តិសិទ្ធិភាពថវិកា តាមរយៈការបន្តខិតខំកែលម្អការវិភាជថវិកាឱ្យកាន់តែចំទិសដៅ និងចំតម្រូវការចាំបាច់ពិតប្រាកដ ជាពិសេសទៅកាន់មុខសញ្ញាដែលជាអាទិភាពសំខាន់ៗចំពោះមុខ និងស្របតាមទិសដៅជាយុទ្ធសាស្ត្រដែលត្រូវបានដាក់ចេញក្នុង «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១» របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា។

### ៣.១.១-ក្របខ័ណ្ឌចំណូលរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩

**១៣-ក្របខ័ណ្ឌចំណូលសរុបថវិការដ្ឋ៖** ស្របតាមក្របខ័ណ្ឌតុល្យភាពរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ ខាងលើ, ចំណូលសរុបថវិការដ្ឋក្នុងឆ្នាំ ២០២៧ ត្រូវបានកំណត់ថានឹងសម្រេចបានក្នុងទំហំប្រមាណ ១៥,២៤% នៃ ផ.ស.ស. គឺកើនប្រមាណ ៩,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦ ក្នុងនោះ៖

- <u>ចំណូលចរន្តថវិការដ្ឋ</u> ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១៤,៧៦% នៃ ផ.ស.ស., គឺកើនក្នុងរង្វង់ ១០,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦ ក្នុងនោះ៖



ទ

➢ ចំណូលសារពើពន្ធថវិការដ្ឋ ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១២,៨៥% នៃ ផ.ស.ស., គឺកើនក្នុងរង្វង់ ១០,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦ ក្នុងនោះ ចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ៥,៨៦% នៃ ផ.ស.ស. ឬកើនក្នុងរង្វង់ ១៤,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦, និង ចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ៦,៩៩% នៃ ផ.ស.ស. ឬកើនក្នុងរង្វង់ ៧,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦។

➢ ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១,៩១% នៃ ផ.ស.ស., ឬកើនក្នុងរង្វង់ ៥,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦។

• ចំណូលផ្សេងៗ ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ០,៤៨% នៃ ផ.ស.ស., ឬថយក្នុងរង្វង់ ១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦។

**ចំណូលសរុបថវិការដ្ឋ ក្នុងរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៨ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៤% ដែលមានទំហំប្រមាណ ១៥,១៦% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩។** ចំណូលចរន្តថវិការដ្ឋ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៣% ដែលនឹងមានទំហំក្នុងរង្វង់ ១៤,៦៨% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩ ដោយក្នុងនោះ ចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានរំពឹងថានឹងសម្រេចបានកំណើនជាមធ្យមក្នុងអត្រា ៧,៨%, ខណៈចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានព្យាករថានឹងសម្រេចបានកំណើនជាមធ្យមក្នុងអត្រា ៦,៧%។ ជាមួយគ្នានេះ, ចំណូលមិនមែនសារពើពន្ធ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យមក្នុងអត្រា ៨,៣% ដែលនឹងមានទំហំក្នុងរង្វង់ ១,៩៤% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩ គាំទ្រដោយការបន្តពង្រឹងការកៀរគរចំណូលពីប្រភពដែលនៅមានសក្តានុពល, ដូចជា ចំណូលពីសម្បទានរ៉ែ និងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ បន្តមានកំណើន, ចំណែកឯ ផលទុនសកម្មភាពទេសចរណ៍ អាករស្ពានទូត ផលទុនរបស់អាកាសចរស៊ីវិល និងចំណូលពីកាតព្វកិច្ចកាស៊ីណូ ក៏ត្រូវបានរំពឹងទុកថានឹងបន្តរើបឡើងដែរ។

ដើម្បីសម្រេចឱ្យបាននូវលទ្ធផលតាមការព្យាករណ៍ខាងលើ និងឆ្លើយតបបានទៅនឹងបញ្ហាប្រឈមលើការប្រមូលចំណូល ព្រមទាំងទ្រទ្រង់បានចលនការនៃចីរភាពកំណើនសេដ្ឋកិច្ច ស្របតាមក្របខ័ណ្ឌចំណូលរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ ខាងលើ, រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តវិធានការគោលនយោបាយស្របតាម **«យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា»** ដែលជារបៀបវារៈកែទម្រង់របស់រាជរដ្ឋាភិបាល ក្នុងការធ្វើទំនើបកម្មប្រព័ន្ធសារពើពន្ធ និងប្រព័ន្ធចំណូលមិនមែនសារពើពន្ធ សំដៅធានាបាននូវការកៀរគរចំណូល ដោយមិនបង្កវិការភាពណាមួយដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍដោយអនុវត្តវិធានការម៉ឺងម៉ាត់ និងមុតស្រួច ទាំងវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកពន្ធដារ ផ្នែកគយនិងរដ្ឋាករ និងផ្នែកចំណូលមិនមែនសារពើពន្ធ ដូចខាងក្រោម៖

• **វិធានការដែលត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន៖**
  - បន្តផ្សព្វផ្សាយ និងពង្រឹងការអនុវត្ត «កម្មវិធីរដ្ឋបាលអេឡិចត្រូនិក ឬ GDT e-Administration» ដែលនឹងក្លាយជាថ្នាលឌីជីថលទំនើប ដើម្បីគាំទ្រពល់ការផ្តល់សេវាអ្នកជាប់ពន្ធ ឱ្យមានភាពកាន់តែងាយស្រួល តាមប្រព័ន្ធអេឡិចត្រូនិក;
  - បន្តសិក្សាពីបច្ច័យនៃការអនុវត្ត Inclusive Framework on Base Erosion Profit Shifting Project ឱ្យបានគ្រប់ជ្រុងជ្រោយ ទាំងក្នុងទិដ្ឋភាពចំណូល ទិដ្ឋភាពបន្ទុករដ្ឋបាលសារពើពន្ធ និងទិដ្ឋភាពបន្ទុកអនុលោមភាពអ្នកជាប់ពន្ធ;

- បន្តពិនិត្យ និងពង្រឹងយន្តការអនុវត្តវិធានការបង្វែរថ្លៃ (Transfer Pricing Rules) ជាពិសេសចំពោះសហគ្រាសបុត្រសម្ព័ន្ធ និងអ្នកជាប់ពន្ធនិវាសនជន ដែលកំពុងទទួលបានការលើកទឹកចិត្តពន្ធ;
- បន្តសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បី (១)- រៀបចំនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) ស្តីពីការជូនវិញ្ញាបនបត្រសម្គាល់អចលនវត្ថុដែលទទួលបានការលើកលែងពន្ធ, (២)- ស្នើសុំទិន្នន័យអចលនទ្រព្យដែលអាចប្រើប្រាស់បានសម្រាប់ប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងពន្ធលើចំណេញមូលធន ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាលកន្លងមក;
- បន្តធ្វើបច្ចុប្បន្នភាពថ្លៃអចលនទ្រព្យ សម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រារៀងរាល់ ៥ ឆ្នាំម្តង ដោយសិក្សាលទ្ធភាពក្នុងការកែសម្រួលប្រកាសស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ;
- បន្តពង្រឹងយន្តការអនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធអាករផ្សេងទៀត លើអាជីវកម្មល្បែងពាណិជ្ជកម្មទាំងសកម្មភាពល្បែងពាណិជ្ជកម្ម និងសកម្មភាពដទៃទៀត ដែលជ្រកក្រោមអាជីវកម្មល្បែងពាណិជ្ជកម្ម;
- ពង្រឹងយន្តការគ្រប់គ្រងចំណូលពន្ធលើវិស័យផលិតស្រាបៀរ និងភេសជ្ជៈ ស្របតាមសេចក្តីណែនាំលេខ ១៥០២៤ ស្តីពីកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះស្រាបៀរ ដែលតម្រូវឱ្យសហគ្រាសផលិតក្នុងស្រុកដំឡើងនូវកុងទ័រ ក្នុងខ្សែចង្វាក់ផលិតកម្ម ដើម្បីវាស់បរិមាណផលិតនៅតាមបំពង់បង្ហូរស្រាបៀរ និងអាចទទួលបានទិន្នន័យភ្លាមៗ ពីទីតាំងផលិត,
- អនុវត្តតឹងរឹងលើវិធានការហាមឃាត់ការផ្តល់រង្វាន់តាមក្រវិលកំប៉ុង ឬគម្របនៃផលិតផលគ្រឿងស្រវឹង និងភេសជ្ជៈ ដើម្បីធានាឱ្យមាននូវតម្លាភាព និងលើកកម្ពស់បរិយាកាសប្រកួតប្រជែងស្មើភាព;
- បន្តពង្រឹងការគ្រប់គ្រងបំណុលពន្ធ និងកំណត់បំណុលពន្ធជាអាទិភាពដែលអាចប្រមូលបានតាមរយៈការធ្វើចំណាត់ថ្នាក់បំណុល ការតឹងទារបំណុល និងបំណុលពន្ធដែលប្រមូលបាន សំដៅកាត់បន្ថយជាអតិបរមានូវបំណុលពន្ធបច្ចុប្បន្ននិងចៀសវាងការកើនឡើងបំណុលពន្ធអនាគត;
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទិន្នន័យចំណាយសារពើពន្ធ ដោយពង្រឹងមុខងារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពន្ធដារ ក្នុងការកត់ត្រាតួលេខការអនុគ្រោះ ការលើកលែង និងការលើកទឹកចិត្តពន្ធនានារបស់រាជរដ្ឋាភិបាល;
- ចូលរួមអនុវត្តវិធានការពាក់ព័ន្ធនឹងពន្ធដារ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីជំរុញវិស័យទាំងនោះឱ្យចូលក្នុងប្រព័ន្ធ ព្រមទាំងលើកទឹកចិត្ត និងថែរក្សាឱ្យវិស័យទាំងនោះក្លាយជាមូលដ្ឋានចំណូលពន្ធបន្ថែម;
- សិក្សាអំពីលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តប្រព័ន្ធ Self-service ជាមគ្គទេសក៍សម្រាប់អ្នកជាប់ពន្ធដើម្បីអាចផ្តល់លទ្ធភាពដល់អ្នកជាប់ពន្ធ ដែលបានចុះបញ្ជីក្នុងប្រព័ន្ធពន្ធដារ អាចដឹងពីប្រភេទពន្ធអាករដែលខ្លួនត្រូវបង់, តាមដានទិន្នន័យបំណុលពន្ធ, ដឹងពីស្ថានភាពនៃការចុះធ្វើសវនកម្ម, និងទិន្នន័យផ្សេងទៀត; និង
- បន្តការងារកែទម្រង់ធនធានមនុស្ស ដោយជំរុញ និងខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធ។

- វិធានការដែលត្រូវអនុវត្តដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា រួមមាន៖
  - បន្តជំរុញការអនុវត្តវិធានការកែទម្រង់គន្លឹះ និងមុតស្រួចផ្នែកកិច្ចសម្រួលពាណិជ្ជកម្ម ក្រោមដែនសមត្ថកិច្ចគយ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាលផ្នែកឯកជន;
  - ជំរុញការអនុវត្តវិធានការមុតស្រួច ក្នុងការបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ និងការពង្រឹងអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលបានដាក់ចេញក្នុងកិច្ចប្រជុំយន្តការភាពជាដៃគូគយផ្នែកឯកជន;
  - ធ្វើវិសិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យាត្រួតពិនិត្យគយ តាមរយៈការបំពាក់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) និងបច្ចេកវិទ្យាទំនើបផ្សេងទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យអនុលោមភាពគយ និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល;
  - បន្តធ្វើបច្ចុប្បន្នភាពច្បាប់ និងបទប្បញ្ញត្តិថ្មី ស្របតាមការវិវឌ្ឍនៃបរិបទសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យា ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការប្រមូលចំណូល ការអនុវត្តច្បាប់ ការទប់ស្កាត់អំពើគេចពន្ធ និងការសម្រួលពាណិជ្ជកម្ម;
  - តាមដានប្រសិទ្ធភាពនៃការអនុវត្តមុខងារគយ និងវិភាគកម្រិតហានិភ័យ ដោយប្រើប្រាស់ថ្នាលរួមដែលវិភាគពីរូបភាពស្កែន, រូបភាពកាមេរ៉ាសុវត្ថិភាព, ប្រព័ន្ធ ECTS, លទ្ធផលជញ្ជីងថ្លឹង, ឯកសារបញ្ជាទំនិញ, ឯកសារដឹកជញ្ជូន និងទិន្នន័យ ឬព័ត៌មាននានា នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគយ;
  - បង្កើនប្រសិទ្ធភាពការគ្រប់គ្រងការអនុវត្តការអនុគ្រោះអត្រាពន្ធ និងការគ្រប់គ្រងទិន្នន័យ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករក្រោមក្របខ័ណ្ឌផ្សេងៗ ពិសេស គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ);
  - បន្តធ្វើវិចារណកម្មតារាងពន្ធគយ ដើម្បីឱ្យមានភាពសមស្របតាមការវិវដ្តសេដ្ឋកិច្ច និងលើកស្ទួយកម្រិតជីវភាពប្រជាជន និងពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករស្របតាមច្បាប់ និងបទប្បញ្ញត្តិថ្មីៗ;
  - បន្តតាមដាន និងវាយតម្លៃការងារបង្ការ និងបង្ក្រាបបទល្មើសគយ ការដាក់ចេញវិធានការមុតស្រួចលើមុខទំនិញជាក់លាក់;
  - ពង្រឹងបន្ថែមសមត្ថភាពជំនាញរបស់មន្ត្រី ដើម្បីឆ្លើយតបឱ្យបានជាអតិបរមាទៅនឹងបទល្មើសគយដែលកើតឡើងក្នុងរូបភាពថ្មីៗ និងកាន់តែស្មុគស្មាញ;
  - លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កែន ដោយត្រូវសិក្សា និងពិនិត្យលទ្ធភាពបំពាក់ម៉ាស៊ីនស្កែន នៅមាត់ច្រកសំខាន់ៗបន្ថែមទៀត ដោយលើកលែងការបង់កម្រៃ ដើម្បីគាំទ្រការពង្រឹងអនុលោមភាពដោយរក្សាបាននូវកិច្ចសម្រួលពាណិជ្ជកម្ម; និង
  - ជំរុញការបង្កើនចំនួននិងសម្រួលនីតិវិធី ដល់ការស្នើសុំវិញ្ញាបនបត្រសមាជិកក្រុមធុរជនល្អបំផុត (Best Traders) និងប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (Authorized Economic Operator Programme - AEO) ក៏ដូចជាកាត់បន្ថយតម្រូវការឯកសាររឹងក្នុងការស្នើសុំ។

- **វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ៖** ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រមូលចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ ពីគ្រប់ប្រភពឱ្យដល់សក្តានុពលដែលមាន, គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម៖
  - បង្កើត និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ ដើម្បីពង្រឹងគណនេយ្យភាព តាមរយៈការរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយនូវលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីពង្រឹងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅក្នុងវិស័យសក្តានុពលសំខាន់ៗ;
  - បែងចែកសមត្ថកិច្ចគ្រប់គ្រង និងប្រមូលចំណូលពីសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ការផ្ទេរមុខងារពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ) និងសិក្សា និងពិនិត្យលទ្ធភាពរៀបចំប្រព័ន្ធបច្ចេកវិទ្យា សម្រាប់ការផ្តល់សេវាតាមប្រព័ន្ធអនឡាញ;
  - ពង្រឹងការគ្រប់គ្រង និងការអនុវត្តលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ តាមរយៈយន្តការពិន័យ ដាក់ទោសទណ្ឌ និងលើកទឹកចិត្ត;
  - ពិនិត្យលទ្ធភាពបង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃសហគ្រាសសាធារណៈ និងភាគហ៊ុនរបស់រដ្ឋ និងសាកល្បងសិក្សាវាយតម្លៃអំពីប្រសិទ្ធភាព ភាពចាំបាច់នៃគោលនយោបាយ និងកម្មវិបាកនៃសហគ្រាសសាធារណៈ;
  - ពន្លឿនការសិក្សាស្រាវជ្រាវអំពីប្រភេទល្បែងពាណិជ្ជកម្មថ្មីៗពីបណ្តាប្រទេសនានា ដើម្បីប្រមូលព័ត៌មាន, ដកស្រង់បទពិសោធ, និងឧត្តមានុវត្តន៍ ដោយផ្តោតលើយន្តការគ្រប់គ្រង និងប្រមូលចំណូលសម្រាប់ជាធាតុចូលក្នុងការតាក់តែងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដាក់ឱ្យដំណើរការប្រភេទល្បែងពាណិជ្ជកម្មថ្មីៗ សំដៅរួមចំណែកពង្រីកសក្តានុពលនៃការប្រមូលចំណូល;
  - បន្តការជំរុញឱ្យប្រើប្រាស់មុខងារទូទាត់តាមរយៈប្រព័ន្ធអេឡិចត្រូនិក ឬ e-Payment;
  - បន្តជំរុញការធ្វើសន្ទានកម្មប្រព័ន្ធ NRMIS និងប្រព័ន្ធ SARMIS ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រព័ន្ធនៃក្រសួង ស្ថាប័នផ្សេងទៀត ឱ្យមានភាពប្រទាក់ក្រឡា និងដំណើរការបានរលូន; និង
  - បន្តសិក្សាស្រាវជ្រាវ និងស្វែងរកប្រភពចំណូលថ្មីៗឱ្យអស់លទ្ធភាព សមស្របតាមស្ថានភាពសេដ្ឋកិច្ច។

### ៣.១.២-ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩

១៤-ក្របខ័ណ្ឌចំណាយសរុបថវិការដ្ឋ៖ ស្របតាមក្របខ័ណ្ឌតុល្យភាពថវិកាឆ្នាំ ២០២៧-២០២៩ ខាងលើ, ចំណាយសរុបថវិការដ្ឋឆ្នាំ ២០២៧ ត្រូវបានគ្រោងក្នុងទំហំ **១៧,០៣%** នៃ ផ.ស.ស. ឬថយប្រមាណ **១,៨%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦។ សម្រាប់ឆ្នាំ ២០២៨-២០២៩, កញ្ចប់ចំណាយសរុបនឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ **៥,៧%** ក្នុងមួយឆ្នាំ ដែលនឹងមានទំហំក្នុងរង្វង់ **១៦,៤៣%** នៃ **ផ.ស.ស.** នៅឆ្នាំ ២០២៩។

- ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងក្នុងទំហំ ១២,៤១% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៧ ដែលមានកំណើនប្រមាណ ៧,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦។ សម្រាប់ឆ្នាំ ២០២៨-២០២៩, ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៥,២% ក្នុងមួយឆ្នាំ ដែលនឹងមានទំហំក្នុងរង្វង់

១១,៨៥% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩។ ចំណាយបន្ទុកបុគ្គលិក **ក្នុងឆ្នាំ ២០២៧** ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ៨,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦ ដោយបានគិតគូរការដំឡើងបៀវត្ស ព្រមទាំងការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការស៊ីវិល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបន្តលើកកម្ពស់ និងគាំទ្រដល់សុខុមាលភាពមន្ត្រីរាជការ ក្នុងកាលៈទេសៈចំពោះមុខនេះ។ សម្រាប់ឆ្នាំ ២០២៨-២០២៩, ចំណាយបន្ទុកបុគ្គលិកត្រូវបានគ្រោងកើនជាមធ្យមក្នុងអត្រា ២,៤%។ ចំពោះចំណាយមិនមែនបន្ទុកបុគ្គលិកក្នុងឆ្នាំ ២០២៧ ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ៦,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦ ស្របតាមគោលការណ៍ពង្រឹងសក្តិសិទ្ធិភាពនៃការវិភាជថវិកា តាមរយៈការខិតខំតម្រង់ការវិភាជថវិកាឱ្យបានត្រឹមត្រូវ និងចំគោលដៅ, បន្តត្បិតត្បៀតលើមុខសញ្ញាចំណាយមិនចាំបាច់ និងមិនសូវចាំបាច់ ព្រមទាំងរក្សាឱ្យបាននូវនិរន្តរភាពប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន និងជាពិសេសគាំទ្រដល់ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់, ការផ្តល់អាទិភាពលើវិស័យសង្គមកិច្ច, ការលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយគាំពារសង្គមសំដៅលើកកម្ពស់សមធម៌ និងភាពសុខដុមក្នុងសង្គម។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល បានគិតគូរបង្កើនធនធានបន្ថែមទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវចែករំលែកចំណូលពីសេវាសាធារណៈក្នុងអត្រា ១៥% សម្រាប់ជាគុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈយន្តការ «**មូលនិធិភាតរភាព**» ចាប់ពីឆ្នាំ ២០២៧ តទៅ និងបានត្រៀមកញ្ចប់ថវិកាក្នុងឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល សម្រាប់អនុវត្តនូវមុខសញ្ញាថ្មីៗ និងកម្មវិធីអន្តរាគមន៍ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងលើកកម្ពស់សមធម៌សង្គម ក្នុងករណីចាំបាច់ផងដែរ។ សម្រាប់ឆ្នាំ ២០២៨-២០២៩, ចំណាយមិនមែនបន្ទុកបុគ្គលិកត្រូវបានគ្រោងកើនជាមធ្យមក្នុងអត្រា ៧,២%។

- **ចំណាយមូលធនថវិកាជាតិ** ត្រូវបានគ្រោងក្នុងទំហំ ៤,៦២% នៃ ផ.ស.ស. **ក្នុងឆ្នាំ ២០២៧ ដែលថយចុះក្នុងអត្រា -១៩,៨%** ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៦។ ការថមថយនេះ បណ្តាលជាចម្បងមកពីចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសឆ្នាំ ២០២៦ មានកំណើនធំ និងការរំពឹងទុកនៃការថមថយប្រភពហិរញ្ញប្បទានក្រៅប្រទេស។ ទោះជាយ៉ាងនេះក្តី, ចំណាយមូលធនក្នុងឆ្នាំ ២០២៧ បន្តផ្តល់ការគិតគូរដល់គម្រោងវិនិយោគសាធារណៈអាទិភាព ស្របតាមគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងតាមលទ្ធភាពថវិកាអាចទ្រទ្រង់បាន។ សម្រាប់ឆ្នាំ ២០២៨-២០២៩ ចំណាយមូលធន ត្រូវបានគ្រោងឱ្យមានកំណើនឡើងវិញ ក្នុងអត្រាជាមធ្យមប្រមាណ ៧,២% ក្នុងមួយឆ្នាំ ដែលនឹងមានទំហំក្នុងរង្វង់ ៤,៥៨% នៃ ផ.ស.ស. នៅឆ្នាំ ២០២៩។ ការគិតគូរឱ្យមានកំណើននេះ គឺដើម្បីឆ្លើយតបតម្រូវការចំណាយចាំបាច់សម្រាប់ការអភិវឌ្ឍ និងសេចក្តីត្រូវការរបស់ប្រជាជន, ការរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច ពោលគឺរាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ទៅលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសតាមរយៈការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការបន្តជួសជុល, ស្តារ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ដែលមានគុណភាពខ្ពស់ និងការបង្កើនបរិមាណ និងគុណភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ការធ្វើបរិវត្តកម្មឌីជីថល។ ជាមួយគ្នានេះដែរ, ទំហំចំណាយវិនិយោគនេះ ក៏បានគិតគូរការវិភាជថវិកាសម្រាប់គាំទ្រដល់ **កម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំ** ក្នុងគោលបំណងពង្រឹងការផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈ ទៅនឹងអាទិភាពគោលនយោបាយនានា ព្រមទាំងធានាភាព-ស្របគ្នារវាងផែនការវិនិយោគ និងផែនការថវិកា សំដៅសម្រេចបានគោលដៅដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨**។

ទន្ទឹមនេះ, ក្របខ័ណ្ឌចំណាយតាមវិស័យឆ្នាំ ២០២៧-២០២៩ ត្រូវបានគិតបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន ទាំងលទ្ធភាពហិរញ្ញប្បទានដោយថវិកាជាតិ និងលទ្ធភាពហិរញ្ញប្បទានក្រៅប្រទេស ទាំងទ្វេភាគី និងពហុភាគី ហើយត្រូវបានកំណត់ដូចតទៅ៖

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៥៩%, ១,៦១%, និង ១,៥៧% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៧, ២០២៨ និង ២០២៩ រៀងគ្នា សំដៅធានានូវប្រសិទ្ធភាពនៃការរៀបចំដំណើរការបោះឆ្នោត, បន្តពង្រឹង និងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការងារការទូតសេដ្ឋកិច្ច ព្រមទាំងបន្តផ្តល់ការគាំទ្រដល់កិច្ចការពារនិងជួយសង្គ្រោះពលករខ្មែរដែលធ្វើការនៅក្រៅប្រទេស, បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, ការងារទាក់ទាញ និងការគ្រប់គ្រងវិនិយោគឯកជន និងការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ, ការធ្វើទំនើបកម្ម និងប្រព័ន្ធស្វ័យប្រវត្តិកម្មរដ្ឋបាលសារពើពន្ធ, ការធ្វើទំនើបកម្មការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ចធុរកិច្ច និងសង្គមឌីជីថល, ការបន្តគាំទ្រការអនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ, ព្រមទាំងការបន្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»។
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ២,៧១%, ២,៦២%, និង ២,៥២% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៧, ២០២៨ និង ២០២៩ រៀងគ្នា សំដៅបន្តពង្រឹងសមត្ថភាពការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី សន្តិសុខ និងសុវត្ថិភាព, ការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការគ្រប់គ្រង និងថែទាំយុទ្ធោបករណ៍ និងសម្ភារៈបច្ចេកទេស, ការអនុវត្តកិច្ចការសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ, ការអនុវត្តកិច្ចការសន្តិសុខមិនប្រពៃណី, ការពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំសង្កាត់មានសុវត្ថិភាព», ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន, ការ-អភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈជូនកងកម្លាំងនគរបាលជាតិ និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃយុត្តិធម៌។
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៤,៨២%, ៤,៨៥%, និង ៤,៧៣% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៧, ២០២៨ និង ២០២៩ រៀងគ្នា **ពោលគឺនៅតែចាត់ទុកជាវិស័យអាទិភាពទី ១** ក្នុងនោះសំដៅបន្តរក្សាលំនឹងជីវភាពប្រជាជន ព្រមទាំងលើកកម្ពស់សមធម៌សង្គម, បន្តលើកកម្ពស់គុណភាពអប់រំ និងគាំទ្រដល់ការពង្រឹង និងពង្រីកការទទួលបានសេវាអប់រំ, ការអភិវឌ្ឍជំនាញដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពិសេសនៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម, លើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាថែទាំសុខភាព ឆ្ពោះទៅការគ្រប-ដណ្តប់សុខភាពជាសកលនៅកម្ពុជា, ជំរុញការអនុវត្តគោលនយោបាយជាតិគាំពារសង្គម, ការបន្តផ្តល់របបសន្តិសុខសង្គម, ការលើកកម្ពស់សមភាពយេនឌ័រ, និងការបន្តគាំទ្រដល់គោលនយោបាយអាទិភាពផ្សេងទៀត ក្នុងផ្នែកសង្គមកិច្ច, សាសនា, វប្បធម៌ និង បរិស្ថាន។

- វិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងប្រមាណ ៣,២៨%, ៣,២១%, និង ៣,២៤% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៧, ២០២៨ និង ២០២៩ រៀងគ្នា ដោយផ្ដោតសំខាន់លើការលើកកម្ពស់ផលិតភាពស្របតាមស្តង់ដា និងតម្រូវការទីផ្សារ, ការលើកកម្ពស់ផលិតភាពកសិកម្ម និងការជួយគ្រួសារកសិករក្នុងការលើកស្ទួយផលិតផលកសិកម្ម តាមរយៈការបន្តដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្ម ទៅគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស និងការរៀបចំឱ្យមានសមាគមកសិកម្មទំនើប, ការគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការជួសជុល និងការថែទាំប្រព័ន្ធធារាសាស្ត្រ ផ្លូវ ស្ពាន និងផ្លូវលំជនបទ, ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ និង ការអភិវឌ្ឍវិស័យថាមពល និងការអនុវត្ត យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ ២០២៣-២០២៨, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥ និង គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០ ។ល។

១៥-ការកំណត់ពិតានចំណាយគោលៈ ផ្អែកលើក្របខ័ណ្ឌចំណាយតាមវិស័យរយៈពេលមធ្យមដែលបានកំណត់ខាងលើនេះ និងលើមូលដ្ឋាននៃការបន្តអនុវត្តសារាចររបស់រាជរដ្ឋាភិបាលស្តីពីវិធានការសន្សំសំចៃលើការប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គិសនី ដែលបានដាក់ចេញក្នុងឆ្នាំ ២០២៦ នេះ ក្នុងបរិការណ៍នៃវិបត្តិថាមពលដែលកំពុងកើតឡើង និងការបន្តអនុវត្តសារាចររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីវិធានការវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ ដោយបានកាត់ព្យួរឥណទានចំណាយប្រេងឥន្ធនៈ និងប្រេងរំអិល ព្រមទាំងចំណាយបេសកកម្មក្នុងប្រទេស និងចំណាយបេសកកម្មក្រៅប្រទេសរបស់ក្រសួង ស្ថាប័នថ្នាក់កណ្ដាល, ចំណាយមិនមែនបន្ទុកបុគ្គលិកតាមវិស័យសម្រាប់ឆ្នាំ ២០២៧ នៅរក្សាកញ្ចប់ស្មើនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៦, ដោយផ្តល់អាទិភាពសម្រាប់ដោះស្រាយតម្រូវការចំណាយចាំបាច់មិនអាចខានបាន ឬមិនអាចពន្យារពេលបាន និងចំណាយតាមគោលការណ៍កំណត់ច្បាស់លាស់។ ក្នុងន័យនេះ, ស្ថិតក្នុងបរិការណ៍ នៃភាពមិនច្បាស់លាស់ពីផលប៉ះពាល់នៃបញ្ហាការអនុវត្តអត្រាពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក, បញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ និងសង្គ្រាមនៅមជ្ឈិមបូព៌ា, ការកំណត់ពិតានចំណាយគោលសម្រាប់ក្រសួង ស្ថាប័នផ្នែកចំណាយមិនមែនបន្ទុកបុគ្គលិក ជាទូទៅត្រូវបានផ្តល់ទាបជាងច្បាប់ថវិកាឆ្នាំ ២០២៦។ ជារួមគឺ ក្រសួង ស្ថាប័ន ត្រូវបានដកចេញនូវសកម្មភាពដែលត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៦ ឬ កាត់បន្ថយមុខចំណាយមិនប្រចាំ, ការកាត់សន្សំបង្កើនសក្តិសិទ្ធិភាពចំណាយ (Spending Efficiency), ព្រមទាំងធ្វើវិចារណកម្មចំណាយមួយចំនួន ជាពិសេសចំណាយដែលអាចសន្សំសំចៃបាន ទាំងលើទិដ្ឋភាពប្រសិទ្ធភាពបច្ចេកទេស និងទាំងលើទិដ្ឋភាពតម្លៃនៃលុយ។ សារៈសំខាន់នៃការកាត់បន្ថយនេះ គឺដើម្បីរក្សាលទ្ធភាពកម្រិតធនធានដែលមានក្នុងឆ្នាំ ២០២៦ ជាលម្ហថវិកាសម្រាប់ដំណាក់កាលពិភាក្សាគម្រោងថវិកាជាមួយក្រសួង ស្ថាប័ន ដើម្បីមានលទ្ធភាពដោះស្រាយតម្រូវការចំណាយថ្មីៗដែលជាកិច្ចការអាទិភាពរបស់ក្រសួង ស្ថាប័ន ជាពិសេសសម្រាប់រាជរដ្ឋាភិបាលមានលទ្ធភាពត្រៀមលក្ខណៈឱ្យបានសមស្របតាមដែលអាចធ្វើទៅបានក្នុងការធ្វើអន្តរាគមន៍ដោះស្រាយសម្ពាធចំណាយថ្មីៗ ដែលអាចកើតឡើងជាយថាហេតុពាក់ព័ន្ធនឹងកិច្ចការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី, ការរក្សាលំនឹងជីវភាពប្រជាជន និងជំរុញជវភាពនៃកំណើនសេដ្ឋកិច្ច។

ស្របតាមវិធីសាស្ត្រ និងអភិក្រម ដូចបានជម្រាបខាងលើនេះ, ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ បានកំណត់ពិតានចំណាយគោលផ្នែកចំណាយចរន្ត សម្រាប់គ្រប់ក្រសួង ស្ថាប័ន, ចំណែកឯ, ពិតានចំណាយគោលផ្នែកចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ ត្រូវបានកំណត់សម្រាប់ក្រសួង ស្ថាប័ន ចំនួន ១១ និង ពិតានចំណាយគោលផ្នែកចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានកំណត់សម្រាប់ក្រសួង ស្ថាប័ន ចំនួន ១០ សម្រាប់ក្រសួង ស្ថាប័នធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងសម្រាប់ការរៀបចំគម្រោងថវិកាឆ្នាំ ២០២៧។

ទន្ទឹមនេះ, ដើម្បីសម្រេចបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងការងើបវិញនូវកំណើនសេដ្ឋកិច្ច, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ចាំបាច់ត្រូវពង្រឹងសក្តិសិទ្ធិភាពថវិកា, ទាំងផ្នែកវិភាជន៍ និងផ្នែកប្រតិបត្តិការ, ដោយឈរលើគោលការណ៍គោរពវិន័យថវិកាប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ និងឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានា តាមរយៈការជំរុញការអនុវត្តវិធានការសំខាន់ៗ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដូចខាងក្រោម៖

- បន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធលើកទឹកចិត្ត ចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ, សមិទ្ធកម្មការងារ, បង្កើនផលិតភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ក៏ដូចជាពិនិត្យលទ្ធភាពដំឡើងបៀវត្ស និងការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ក្នុងគោលដៅរក្សាលំនឹងជីវភាពរស់នៅរបស់មន្ត្រីគ្រប់ថ្នាក់,
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី, ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព,
- បន្តតម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់ បរិយាប័ន្ន និងចីរភាព តាមរយៈការផ្តល់អាទិភាពទៅលើការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់រចនាសម្ព័ន្ធ, ការអភិវឌ្ឍមូលធនមនុស្ស, និងការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការជំរុញការធ្វើបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍបៃតង,
- ផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធភាពចំណូល ដែលមានប្រភពពីការប្រមូលចំណូលក្នុងប្រទេស ដោយខិតខំមិនប្រើប្រាក់សន្សំរបស់រាជរដ្ឋាភិបាល លើកលែងតែករណីចាំបាច់បំផុត ដើម្បីរក្សាតុល្យភាព និងចីរភាពថវិកា តាមរយៈការធ្វើអាទិភាវូបនីយកម្មចំណាយ និងពង្រឹងសក្តិសិទ្ធិភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ,
- ពង្រឹងនីតិវិធីនៃការគ្រប់គ្រង, រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ និងការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ,
- បន្តរក្សាចីរភាពបំណុលរយៈពេលមធ្យម និងវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប តាមរយៈការកំណត់ពិតាននៃការខ្ចីប្រចាំឆ្នាំ និងការធានារបស់រដ្ឋ, ការកំណត់សូចនាករបំណុលគន្លឹះសំខាន់ៗ, ការកំណត់គោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទាន និងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយ, និង
- បន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព, សក្តិសិទ្ធិភាព, តម្លាភាព និងគណនេយ្យភាពនូវ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០២៤-២០២៨ សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព

ជាពិសេស វិស័យបង្កើនផលិតភាព និងតម្លៃបន្ថែម, ជំរុញការតភ្ជាប់, និងពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច។

## ៤-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងការរៀបចំថវិកាឆ្នាំ ២០២៧

១៦-ផ្អែកលើក្របខ័ណ្ឌថវិកាឆ្នាំ ២០២៧-២០២៩ និងពិតានចំណាយគោល *ដូចមានភ្ជាប់ក្នុងតារាង ១ និងតារាង ១.១,* គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងគម្រោងថវិកាឆ្នាំ ២០២៧ របស់ខ្លួន តាមគោលការណ៍ និងបច្ចេកទេស ដូចខាងក្រោម៖

### ៤.១-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩

១៧-ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ ១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល, ២)-បង្កើនវិចារណកម្មអាទិភាពចំណាយរបស់ក្រសួង ស្ថាប័ន, ៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង ស្ថាប័ន, ៤)-ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់ការងារអាទិភាព និង ៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។

១៨-ដូចនេះ, ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការួមមួយ ដែលត្រូវគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដោយត្រូវធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាដោយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពកាន់តែប្រសើរ ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ជួយលើកកម្ពស់សក្តិសិទ្ធិភាពនៃការវិភាជថវិកាប្រចាំឆ្នាំ។ ក្នុងន័យនេះ, *ក្រសួង ស្ថាប័ននីមួយៗ ត្រូវពង្រឹងក្រុមការងារថវិការបស់ខ្លួន ដែលមានអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ/អគ្គលេខាធិការដ្ឋាន ជា "អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ", ទទួលបន្ទុកសម្របសម្រួល និងការចូលរួមប្រកបដោយបុរេសកម្មពីអង្គភាពថវិកា ដែលជាអគ្គនាយកដ្ឋាន និងអង្គភាពជំនាញ ព្រមទាំងអង្គភាពគ្រប់គ្រងគម្រោង* ដើម្បីធានាបាននូវផែនការយុទ្ធសាស្ត្រថវិកាដែលមានគុណភាព និងភាពគ្រប់ជ្រុងជ្រោយ។

១៩-ផ្អែកលើកញ្ចប់ថវិកាដែលត្រូវបានកំណត់ក្នុងពិតានចំណាយគោល, ក្រសួង ស្ថាប័ននីមួយៗត្រូវរៀបចំផែនការថវិការយៈពេលមធ្យម (៣ ឆ្នាំ) ដោយត្រូវគោរពតាមពិតានចំណាយគោលដែលបានផ្តល់ជូន។ ជាមួយគ្នានេះ, ក្រសួង ស្ថាប័នត្រូវបានអនុញ្ញាតឱ្យគ្រោងនូវតម្រូវការធនធានថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីៗ ដែលជាយថាហេតុទើបទទួលបានការសម្រេចពីរាជរដ្ឋាភិបាលនៅក្នុងឆ្នាំអនុវត្តថវិកានេះ។ ដូចនេះ, ក្រុមការងារថវិកាត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារអាទិភាពទាំងអស់របស់ក្រសួង ស្ថាប័នសាមី ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រថវិកា ដើម្បីធានាថាថវិកាត្រូវបានវិភាជចំអាទិភាព សកម្មភាព និងចំសេចក្តីត្រូវការយ៉ាងពិតប្រាកដរបស់អង្គភាពអនុវត្តនីមួយៗ និងឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណងគោលនយោបាយ និងកម្មវិធីរបស់ក្រសួង ស្ថាប័ន។ គ្រប់ក្រសួង ស្ថាប័នត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន តាមទម្រង់ដូចមានភ្ជាប់ក្នុង **ឧបសម្ព័ន្ធ ១**។



ស

២០-ដើម្បីពង្រឹងការអនុវត្ត *អនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា* ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់, ក្រសួង ស្ថាប័ន ត្រូវកំណត់ **អង្គភាពថវិកា** និងអ្នកគ្រប់គ្រង ទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព) ឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យមានបន្ទាត់គណនេយ្យភាពដែលមានការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងថវិកា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្តល់ការបណ្តុះបណ្តាលសមត្ថភាពផ្នែកថវិកា និងនីតិវិធីហិរញ្ញវត្ថុ ក៏ដូចជាផ្តល់ប្រឹក្សាផ្នែកបច្ចេកទេសពាក់ព័ន្ធ តាមការចាំបាច់ជូនដល់ទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ដើម្បីមានសមត្ថភាពពេញលេញក្នុងការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម។

### ៤.១.១-ការគ្រោងចំណូលថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩

២១-ការគ្រោងចំណូល គឺត្រូវគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៧-២០២៩ ដោយរួមទាំងចំណូល ដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ និងប្រភពផ្សេងៗទៀត។ ក្នុងការគ្រោងចំណូល ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- វាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត ដើម្បីគ្រោងចំណូលឆ្នាំ ២០២៧ និងព្យាករចំណូលឆ្នាំ ២០២៨-២០២៩
- ដាក់ចេញវិធានការដាក់ស្តែងបន្ថែមទៀតតាមក្រសួង ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល។

ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ត្រូវរៀបចំផ្នែកនេះ ទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរនេះ**។ នៅក្នុងផ្នែកនេះ, ចំពោះក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ។

ទន្ទឹមនេះ, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ដែលមានប្រភពចំណូល គឺត្រូវដាក់ចេញវិធានការដាក់ស្តែងថ្មីៗបន្ថែមទៀត សម្រាប់ពង្រឹងការគ្រប់គ្រង និងខិតខំប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យអស់សក្តានុពល។ *ផ្ទុយទៅវិញ, ការគ្រោងចំណូលមិនអស់សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតផ្នែកចំណាយជំនួសវិញ នៅក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន ដែលមានការកិច្ចប្រមូលចំណូល។*

### ៤.១.២-ការគ្រោងចំណាយថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩

២២-ការគ្រោងតម្រូវការចំណាយ គឺជាការគណនាតម្រូវការសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៧-២០២៩ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន ទាំងថវិកាជាតិ និងទាំងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរនេះ**។



ៗ

ក្នុងការគណនាអំពីតម្រូវការចំណាយ ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើមូលដ្ឋានសំខាន់ៗ ដូចខាងក្រោម៖

ទី១-ពិតានចំណាយគោល ដែលបានផ្តល់ជាកញ្ចប់ថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (២០២៧-២០២៩)

ទី២-ការវាយតម្លៃការអនុវត្តចំណាយក្នុងឆ្នាំកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០២៦ ដែលបាននិងកំពុងអនុវត្ត,

ទី៣-ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ដោយត្រូវគណនាតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ និងត្រូវស្របតាមបញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា ដែលបានកំណត់និងដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវគិតគូរដោយឈរលើទិដ្ឋភាព ៣ ជាសំខាន់ រួមមាន៖

- ផែនការសកម្មភាពការងារ ឬ គម្រោងមានស្រាប់ ដែលត្រូវបន្តអនុវត្ត,
- សកម្មភាពការងារដែលបញ្ចប់ត្រឹមមួយឆ្នាំ, និង
- សកម្មភាពការងារថ្មី តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

ដូច្នេះ, ផ្អែកលើមូលដ្ឋាននៃទិដ្ឋភាពទាំង ៣ ខាងលើនេះ, គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងចំណាយសម្រាប់ឆ្នាំ ២០២៧-២០២៩ តាមគោលការណ៍បច្ចេកទេស ដូចខាងក្រោម៖

- ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)៖ សម្រាប់ឆ្នាំ ២០២៧, ក្រសួង ស្ថាប័ននីមួយៗត្រូវគ្រោងចំណាយបន្ទុកបុគ្គលិកទៅតាមគោលការណ៍ណែនាំលម្អិតសម្រាប់ការជ្រើសរើសចំនួនក្របខ័ណ្ឌថ្មី និងសម្រាប់ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ និងបុណ្យភ្ជុំបិណ្ឌ ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន, ដែលមានចែងក្នុងផ្នែកបន្ទាប់ខាងក្រោមត្រង់ចំណុច (ក) នៃផ្នែក ៤.២.២-អំពីការគ្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០២៧។ ដោយឡែក, សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០២៨ និងឆ្នាំ ២០២៩ ត្រូវគ្រោងក្នុងកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០២៧ និងឆ្នាំ ២០២៨ រៀងៗគ្នា ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ និងផ្អែកលើការវិភាគមុខងារដែលទទួលបានការឯកភាពពីក្រសួងមុខងារសាធារណៈ។
- ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)៖ ត្រូវគ្រោងតាមគោលការណ៍ ដូចខាងក្រោម៖

- ក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្តាល៖ ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៧-២០២៩ ប៉ុន្តែ កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះនឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ គឺនៅជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សា ដើម្បីបង្កើនសក្តិសិទ្ធិភាពក្នុងការវិភាជថវិកា និងប្រតិបត្តិការចំណាយ។ ក្នុងន័យនេះ, ក្រសួង ស្ថាប័នត្រូវកាត់ចេញនូវចំណាយលើមុខសញ្ញាចំណាយ ឬសកម្មភាពការងារណា ដែលត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៦ ឬចំណាយមិនប្រចាំដែលមិនចាំបាច់និងលែងចាំបាច់ និងចំណាយដែលអាចពន្យារពេលបាន ដើម្បីរក្សាលម្ហថវិកាសម្រាប់សកម្មភាពការងារថ្មី ឬគម្រោងថ្មី ដែលទើបមានការសម្រេចរបស់រាជរដ្ឋាភិបាល ឬដែលក្រសួង ស្ថាប័នមានតម្រូវការអនុវត្តជាចាំបាច់ នៅក្នុងឆ្នាំអនុវត្តថវិកា។ ទន្ទឹមនេះ, រាល់ការគ្រោងចំណាយទាំងអស់ត្រូវភ្ជាប់

ជាមួយនូវឯកសារពាក់ព័ន្ធ រួមមាន៖ ការសិក្សា, វិភាគ, វាយតម្លៃ និងការផ្តល់អំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងការពិភាក្សាការពារគម្រោងថវិកា នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ។

- **មន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើកញ្ចប់ពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី ខេត្ត, ត្រូវគ្រោងយ៉ាងច្រើនបំផុតស្មើនឹងកម្រិតថវិកាអតិបរមានៃកញ្ចប់ពិតានចំណាយគោលនេះ។ ប៉ុន្តែ **ត្រូវកត់សម្គាល់ថា កញ្ចប់ថវិកាដែលគ្រោងផ្តល់នេះ មិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវ**ផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក, សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ, ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិនៃក្រសួង ស្ថាប័ននីមួយៗ** ត្រូវបានផ្តល់ពិតានចំណាយគោលសម្រាប់ឧបត្ថម្ភធនរយៈពេល ៣ ឆ្នាំ (ឆ្នាំ ២០២៧-២០២៩) ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវនិងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត, ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- **ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក ២១)៖ ត្រូវបានផ្តល់ពិតានចំណាយគោលសម្រាប់ក្រសួង ស្ថាប័នចំនួន ១១ រួមមាន៖ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្រសួងទាំង ១១ ត្រូវរៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាបញ្ជីគម្រោងសម្រាប់ឆ្នាំ ២០២៧-២០២៩ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី និងដោយភ្ជាប់ជាមួយនូវបញ្ជីគម្រោងដែលបានរៀបចំ។ ទោះយ៉ាងនេះក្តី, ក្រសួងទាំង ១១ ខាងលើនេះ នឹងមិនទទួលបានកញ្ចប់ចំណាយវិនិយោគជាស្វ័យប្រវត្តិទេ, ការធ្វើអាទិភាវូបនីយកម្មគម្រោង និងការផ្តល់ថវិកា គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ និងក្រុមការងារអន្តរក្រសួង។ ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលមានតម្រូវការចំណាយវិនិយោគ ក៏ត្រូវចាប់ផ្តើមសិក្សារៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ឱ្យច្បាស់លាស់ និងរៀបចំលើកសំណើគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំធ្វើអាទិភាវូបនីយកម្មគម្រោងតាមការចាំបាច់ ហើយគោរព

ស្នើសុំរាជរដ្ឋាភិបាល ពិនិត្យសម្រេចតាមលទ្ធភាពថវិកា និងតាមវិធានការផ្នែកចំណាយដែលបានកំណត់នៅផ្នែកខាងលើនៃសារាចរនេះ។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ៖** ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង ស្ថាប័នចំនួន ១០ រួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ចំពោះក្រសួង ស្ថាប័នដទៃទៀត ដែលបាន និងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៧-២០២៩) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

## ៤.២-គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០២៧

២៣-ផ្អែកលើក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ក្រសួង ស្ថាប័ននីមួយៗ ត្រូវគ្រោងចំណូល ចំណាយឆ្នាំ ២០២៧ តាមគោលការណ៍និងបច្ចេកទេស ដូចខាងក្រោម៖

### ៤.២.១-ការគ្រោងចំណូលថវិកាឆ្នាំ ២០២៧

២៤-ការគ្រោងចំណូលថវិកាចរន្ត គឺផ្អែកលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ និងដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ។ ដូចនេះ, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគិតគូរគម្រោងចំណូលថវិការបស់ខ្លួន តាមគោលការណ៍ ដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖
    - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងអនុវត្ត (ឆ្នាំ ២០២៦);
    - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ និងការប្រមូលបំណុលពន្ធដែលត្រូវទារ;
    - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ;
    - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រានិងមូលដ្ឋានប្រមូលពន្ធ។
- ចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមគោលការណ៍ ដូចខាងក្រោម៖
    - **ផ្នែកចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ៖** ត្រូវបន្តសិក្សាលទ្ធភាពកែសម្រួលកម្រៃសេវា និងអត្រាសួយសារពាក់ព័ន្ធនឹងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងការកែសម្រួលកិច្ចសន្យាសម្បទានគ្រប់ប្រភេទ និងកិច្ចសន្យាជួលសេវាកម្មគ្រប់ប្រភេទ, ត្រូវពិនិត្យ និងជំរុញក្រុមហ៊ុនដែលទទួលបានសិទ្ធិពីរដ្ឋសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនដែលធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ ឧស្ម័ន និងប្រេងកាត ជាដើម ឱ្យបន្តដំណើរការអនុវត្តតាមកិច្ចសន្យា ឬចាត់វិធានការ

សមស្របចំពោះករណីមិនមានអនុលោមភាព ព្រមទាំងត្រូវបន្តកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលបំណុលដែលត្រូវទារ ជាដើម ។ល។

- **ផ្នែកចំណូលមិនមែនសារពើពន្ធ៖** ត្រូវអនុវត្តម៉ឺងម៉ាត់តាមវិធានការផ្នែកចំណូលមិនមែនសាពើពន្ធ ដែលបានកំណត់នៅទំព័រទី ១២ នៃសារាចរនេះ។ ទន្ទឹមនេះ, ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគិតគូរ ដាក់ចេញនូវវិធានការដាក់ស្តែងបន្ថែម ដើម្បីពង្រឹងការកៀរគរ៖
  - ចំណូលពីប្រភពដែលនៅមានសក្តានុពល មានដូចជា ចំណូលពីសម្បទានរ៉ែ, ចំណូលពីវិស័យប្រៃសណីយ៍និងទូរគមនាគមន៍, ផលទុនសកម្មភាពទេសចរណ៍, អាករស្ពានទូត និងផលទុនរបស់អាកាសចរស៊ីវិល ដែលត្រូវបានរំពឹងទុកថានឹងមានកំណើន,
  - ចំណូលដែលអាចមានកំណើន តាមរយៈការពង្រឹងអភិបាលកិច្ចស្ថាប័ន ដោយត្រូវរៀបចំដាក់ចេញនូវផែនការសកម្មភាពជាក់លាក់នៅតាមក្រសួង ស្ថាប័ន។

### ៤.២.២- ការគ្រោងចំណាយថវិកាឆ្នាំ ២០២៧

២៥-ថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅខ្លីថា "ថវិកាសមិទ្ធកម្ម" ត្រូវបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ ២០២៦ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ដូចនេះ, **ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវជំរុញលើកកម្ពស់សក្តិសិទ្ធិភាពនៃការវិភាជ ដោយត្រូវផ្តោតការយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងលើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងត្រូវសម្រេចបាន ចំពោះកម្មវត្ថុចំណាយ ឬមុខសញ្ញាចំណាយ ឬគម្រោងចំណាយនីមួយៗ។ ក្នុងន័យនេះ, ក្រសួង ស្ថាប័នត្រូវពង្រឹងបន្ថែមនូវប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការពិភាក្សាការពារគម្រោងថវិកា ក៏ដូចជាសម្រាប់ការធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ, ក្រសួង ស្ថាប័ន ក៏ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែស៊ីសង្វាក់គ្នា និងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ, ម្យ៉ាង, ដើម្បីសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់ និងម្យ៉ាងទៀត, ដើម្បីសម្រួលដល់ការអនុវត្តថវិកាឱ្យកាន់តែរលូនល្អផងដែរ។ ជាមួយគ្នានេះ, *ក្រសួង ស្ថាប័ន ត្រូវយកចិត្តទុកដាក់ក្នុងការកំណត់គោលបំណង និងកត្តាកំណត់ជោគជ័យនៃកម្មវិធី និងអនុកម្មវិធី ឱ្យបានល្អ ដើម្បីធានាបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ពិសេសត្រូវកំណត់សូចនាករគន្លឹះ និងគោលដៅសូចនាករឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។*

២៦-ការរៀបចំផែនការសមិទ្ធកម្ម៖ ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការសមិទ្ធកម្ម (សូចនាករគន្លឹះ និងគោលដៅសូចនាករ) ប្រចាំឆ្នាំ ដូចមានភ្ជាប់ក្នុង **តារាង ក** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យអនុលោមភាព និងចងក្រង ដាក់ជាឯកសារឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧ ព្រមទាំងសម្រាប់ជាកម្មវត្ថុនៃការតាមដានវឌ្ឍនភាពនៃការអនុវត្តថវិកាសមិទ្ធកម្ម។ ក្នុងន័យនេះ, ក្រសួង ស្ថាប័នត្រូវផ្ញើផែនការសមិទ្ធកម្ម ដោយភ្ជាប់មកជាមួយនឹងគម្រោងថវិកាឆ្នាំ ២០២៧ របស់ខ្លួនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *(អគ្គនាយកដ្ឋានថវិកា)* តាមកាលបរិច្ឆេទកំណត់ក្នុងសារាចរនេះ។

ទន្ទឹមនេះ, ក្នុងគោលបំណងកែលម្អទម្រង់ផែនការសមិទ្ធកម្មប្រចាំឆ្នាំ ឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លុះបញ្ចាំងពីគោលដៅរយៈពេលមធ្យម ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ, គ្រប់ក្រសួង ស្ថាប័ន ត្រូវបន្ថែម និងកែសម្រួលព័ត៌មានចាំបាច់មួយចំនួន ក្នុងផែនការសមិទ្ធកម្មប្រចាំឆ្នាំ ២០២៧ ដូចខាងក្រោម៖

**ក- ព័ត៌មានដែលត្រូវបញ្ចូលបន្ថែមក្នុងផែនការសមិទ្ធកម្ម រួមមាន៖**

- គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន
- ឯកតា ដែលជារង្វាស់នៃសូចនាករ សម្រាប់កំណត់ការវាស់វែងវឌ្ឍនភាពរបស់សូចនាករ (ឧទាហរណ៍ : ភាគរយ (%), អត្រា, ចំនួន, ចំនួនដង, ។ល។)
- គោលដៅសូចនាករសម្រាប់ឆ្នាំ N+2 (២០២៨) និង ឆ្នាំ N+3 (២០២៩) និង
- ប្រភពទិន្នន័យសម្រាប់សូចនាករនីមួយៗ ដែលសំដៅដល់អង្គភាពទទួលបន្ទុកវាស់វែងសូចនាករ។

**ខ- ព័ត៌មានដែលត្រូវកែសម្រួល មានដូចជា៖**

ក្នុងករណីចាំបាច់ ក្រសួង ស្ថាប័ន អាចកែសម្រួលគោលបំណងនៃកម្មវិធីដែលវែងពេក និងមានលក្ខណៈស្មុគស្មាញឱ្យទៅជាគោលបំណងតូចៗ ប៉ុន្តែមិនត្រូវមានចំនួនលើសពីបីក្នុងមួយកម្មវិធីនោះទេ។ ទន្ទឹមនេះ, សូចនាករដែលមានស្រាប់នៅក្នុងកម្មវិធីនីមួយៗ ក៏ត្រូវបែងចែកទៅតាមគោលបំណងតូចៗនៃកម្មវិធីដែលសូចនាករនោះត្រូវវាស់វែងផងដែរ។ ជារួម, កម្មវិធីនីមួយៗត្រូវមានសូចនាករលទ្ធផលចុងក្រោយមិនលើសពីបី។ ក្រសួង ស្ថាប័ន ដែលស្នើសុំប្រើប្រាស់សូចនាករនៅកម្រិតកម្មវិធីលើសពីបី ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ- កម្មវិធី "ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ"៖**

ក្រសួង ស្ថាប័ន ដែលមានកម្មវិធីលើសពីមួយ និងមានកម្មវិធី "ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ" នៅក្នុងកម្មវិធីចុងក្រោយ ដែលជាកម្មវិធីគាំទ្រ ត្រូវមានសូចនាករលទ្ធផលចុងក្រោយចំនួនពីរជាអប្បបរមា ដូចខាងក្រោម៖

| សូចនាករ | ឯកតា | គោលដៅ |
|---|---|---|
| ១. ភាគរយនៃការអនុវត្តថវិកាធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ | % | ធំជាង ឬស្មើ ៩៥% |
| ២. ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង * | % | ធំជាង ឬស្មើ ៦០% (ត្រូវបានពង្រឹង) |

ក្រសួង ស្ថាប័ន អាចគណនា និងវាស់វែងសូចនាករទី២ "ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង" តាមរយៈការកំណត់សូចនាកររង។ សូចនាកររង សំដៅដល់សូចនាករនៅកម្រិតអនុកម្មវិធីដែលពាក់ព័ន្ធនឹងការងារស្នូលចំនួន ៥ ដូចខាងក្រោម៖

- ការគ្រប់គ្រងធនធានមនុស្ស មានជាអាទិ៍ការងារពាក់ព័ន្ធនឹងការបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងភាពទាន់ពេលនៃការបើកប្រាក់បៀវត្ស។
- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ រួមមានការងារពាក់ព័ន្ធនឹងបច្ចុប្បន្នភាពទិន្នន័យទ្រព្យសម្បត្តិរដ្ឋជាដើម។

- ការតាមដាននិងវាយតម្លៃ មានជាអាទិ៍ ការងារពាក់ព័ន្ធនឹងការចុះតាមដាន ត្រួតពិនិត្យសមិទ្ធកម្ម, ការរៀបចំផែនការ និងរបាយការណ៍សមិទ្ធកម្ម។
- សវនកម្មផ្ទៃក្នុង រួមមានការចុះធ្វើសវនកម្មផ្ទៃក្នុង និងការអនុលោមតាមអនុសាសន៍សវនកម្មជាដើម។
- អភិបាលកម្មឌីជីថល សំដៅដល់ការងារពាក់ព័ន្ធនឹងការប្រើប្រាស់ឌីជីថលជារួម ប្រកបដោយការយល់ដឹង និងការទទួលខុសត្រូវ។

ក្រសួង ស្ថាប័ន មានភាពបត់បែនក្នុងការរៀបចំសូចនាកររងពាក់ព័ន្ធនឹងការងារស្នូលយ៉ាងតិចចំនួន ២ ក្នុងចំណោមការងារស្នូលទាំង ៥ ខាងលើ ទៅតាមស្ថានភាពការងារជាក់ស្តែងរបស់ក្រសួង ស្ថាប័ន នីមួយៗ ប៉ុន្តែត្រូវធានាឱ្យបាននូវលក្ខណៈវិនិច្ឆ័យរបស់សូចនាកររួមមាន៖ ការផ្តោតលើលទ្ធផល, អាចវាស់វែងបាន, ងាយយល់, មានសុពលភាព, និងអាចទុកចិត្តបាន។ បន្ទាប់ពីក្រសួង ស្ថាប័ន មានសូចនាកររងពាក់ព័ន្ធនឹងការងារស្នូល ចាប់ពី ២ ឡើងទៅ, ក្រសួង ស្ថាប័ន អាចវាស់វែងសូចនាករ "ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង" ដោយយកភាគរយនៃលទ្ធផលសម្រេចបានរបស់សូចនាកររងនីមួយៗ បូកបញ្ចូលគ្នា និងគណនារកមធ្យមភាគ ដើម្បីអាចធ្វើការសន្និដ្ឋានបានដូចខាងក្រោម៖

- មធ្យមភាគ ចាប់ពី ៦០% ឡើងទៅ មានន័យថា "ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានពង្រឹង"។
- មធ្យមភាគ ក្រោម ៦០% មានន័យថា "ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង មិនត្រូវបានពង្រឹង"។

**២៧-កិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវបានកំណត់ជា ៣ កម្រិត៖** *(ទី១)-រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី, (ទី២)-រវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង ស្ថាប័នសាមី, និង (ទី៣)-រវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា ដូចមានភ្ជាប់នូវគំរូកិច្ចព្រមព្រៀងសមិទ្ធកម្មទាំង ៣ កម្រិតនេះ។ ដូចនេះ, ក្រសួង ស្ថាប័ន ត្រូវរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្ម តាមកញ្ចប់ថវិកាដែលទទួលបានការឯកភាព និងវិភាជជូន តាមស្មារតីនៃការពិភាក្សាការពារគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។*

**២៨-**គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងលម្អិតតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា (ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងការពារគម្រោងថវិកាផងដែរ។ លើសពីនេះ, ការគណនាតម្រូវការចំណាយត្រូវផ្អែកលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ ២០២៥ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០២៦ និងដោយផ្អែកលើថ្លៃឯកតា ស្របតាម

បញ្ជីស្តង់ដារថ្លៃទំនិញ និងសេវាដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬថ្លៃទីផ្សារ (ក្នុងករណីមិនមានកំណត់ក្នុងបញ្ជីស្តង់ដារថ្លៃទំនិញនិងសេវា) ក៏ដូចជា តាមគោលរបបកំណត់ ជាដើម។ ដូចនេះ, ស្របតាមផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំនិងដាក់ឱ្យអនុវត្តនូវស្តង់ដារថ្លៃទំនិញ និងសេវាសម្រាប់កិច្ចលទ្ធកម្មសាធារណៈ ដើម្បីធានាបាននូវតម្លាភាព, គណនេយ្យភាព និងសក្តិសិទ្ធិភាពនៃចំណាយសាធារណៈ ដោយពង្រីកវិសាលភាពនៃការអនុវត្តសម្រាប់ការរៀបចំថវិកាឆ្នាំ ២០២៧ ទៅដល់ ២០ ក្រសួង ស្ថាប័ន រួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងយុត្តិធម៌, ក្រសួងរ៉ែនិងថាមពល, ក្រសួងធម្មការនិងសាសនា, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងមហាផ្ទៃ, ក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងកិច្ចការនារី, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងមុខងារសាធារណៈ, អាជ្ញាធរសវនកម្មជាតិ, ក្រុមប្រឹក្សាធម្មនុញ្ញ, រដ្ឋសភា, ព្រឹទ្ធសភា, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសុខាភិបាល, ក្រសួងព័ត៌មាន និងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

២៩-ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មានក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩, **សម្រាប់ឆ្នាំ ២០២៧ ក្នុងកម្រិតនៃកញ្ចប់ពិតានចំណាយគោលដែលបានផ្តល់ជូន ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងចំណាយរបស់ខ្លួន**ទៅតាមគោលការណ៍ និងបណ្តាវិធានការ ដូចខាងក្រោម៖

ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក ៦៤)៖ នាយកដ្ឋានបុគ្គលិក/អង្គភាពគ្រប់គ្រងធនធានមនុស្ស ដែលជាសេនាធិការរបស់ក្រសួង ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួល និងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតតាមគោលការណ៍ ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ពោលគឺត្រូវចៀសវាងការគ្រោងបៀវត្ស ឬបន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោល។ ក្នុងន័យនេះ, ការគ្រោងចំណាយបន្ទុកបុគ្គលិកសម្រាប់ឆ្នាំ ២០២៧ ត្រូវអនុវត្តនូវគោលការណ៍លម្អិត ដូចខាងក្រោម៖

- ចំនួនក្របខ័ណ្ឌថ្មី ត្រូវគ្រោងយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ក្នុងឆ្នាំ ២០២៦ ប៉ុន្តែការជ្រើសរើសជាក់ស្តែងគឺជាកម្មវត្ថុនៃការឯកភាពពីក្រសួងមុខងារសាធារណៈ។ ទន្ទឹមនេះ, ចំពោះមន្ត្រីដែលព្យួរការងារ និងមន្ត្រីដែលចូលបម្រើការងារវិញ ក៏ត្រូវគ្រប់គ្រង និងគ្រោងថវិកាឱ្យបានត្រឹមត្រូវ និងហ្មត់ចត់។
- សន្ទស្សន៍បៀវត្សមូលដ្ឋាន ត្រូវរក្សាស្មើនឹងកម្រិតឆ្នាំ ២០២៦ (តម្លៃសន្ទស្សន៍ក្នុង ១ ឯកតាស្មើនឹង ២ ៦៣០ រៀល)។ ទន្ទឹមនេះ, ក្រសួង ស្ថាប័នអាចគ្រោងថវិកាសម្រាប់ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ស្របតាមបទប្បញ្ញត្តិជាធរមាន។
- ប្រាក់បំណាច់មុខងារ ត្រូវដំឡើងប្រាក់បំណាច់មុខងារប្រចាំខែចំនួន ៥ ម៉ឺនរៀល ជូនដល់មន្ត្រីរាជការ-ស៊ីវិល, មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារក្រោម ៨០០ ០០០ រៀល និងដំឡើងប្រាក់បំណាច់មុខងារប្រចាំខែចំនួន ៣ ម៉ឺនរៀល ជូនដល់មន្ត្រីរាជការស៊ីវិល, មន្ត្រី-នគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារចាប់ពី ៨០០ ០០០ រៀល ឡើងទៅដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។

- ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ ត្រូវគ្រោងចំនួន ៥ ម៉ឺនរៀល ក្នុងម្នាក់ និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ត្រូវគ្រោងចំនួន ៥ ម៉ឺនរៀល ក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន, និង
- មន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងមិនឱ្យលើសពីចំនួន ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២៦ និងដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះមន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោងដំឡើងពី ៧៩ ម៉ឺនរៀល ទៅដល់ ៨១ ម៉ឺនរៀល ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។

ជាមួយគ្នានេះ, សម្រាប់ឆ្នាំ ២០២៧, រាជរដ្ឋាភិបាលបានត្រៀមបម្រុងកញ្ចប់ថវិកាដោយឡែកផងដែរសម្រាប់ការដំឡើងប្រាក់សោធន ជូននិវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ ដើម្បីជួយទ្រទ្រង់ ជីវភាពបានសមរម្យ ដែលគោលការណ៍លម្អិតសម្រាប់ការអនុវត្ត នឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

ទន្ទឹមនេះ, សម្រាប់ការគ្រោងថវិកាឆ្នាំ ២០២៧, គ្រប់ក្រសួង ស្ថាប័ន (**ទាំងថ្នាក់កណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត**) ត្រូវគ្រោងចំណាយបន្ទុកបុគ្គលិក ទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម។ ក្នុងន័យនេះ, គ្រប់ក្រសួង ស្ថាប័ន ត្រូវពិនិត្យឱ្យហ្មត់ចត់លើការអនុវត្តជាក់ស្តែង នាឆ្នាំកន្លងទៅ និងឆ្នាំកំពុងអនុវត្ត ដើម្បីបង្កើនសុក្រឹតភាពដល់ការគ្រោងចំណាយបន្ទុកបុគ្គលិកទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ។

**ខ-ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)៖** ចំពោះមុខនៃវិបត្តិថាមពល នៅក្នុងឆ្នាំ ២០២៦ នេះ ដែលបណ្តាលឱ្យមានការកើនថ្លៃប្រេងឥន្ធនៈ និងថ្លៃដើមលើការផលិតអគ្គិសនី គ្រប់ក្រសួង ស្ថាប័ន ត្រូវបន្តអនុវត្តសារាចររបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញស្តីពីវិធានការសន្សំសំចៃលើការប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គិសនី និងសារាចររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានដាក់ចេញស្តីពីវិធានការវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ ដោយត្រូវកាត់សន្សំចំណាយលើប្រេងឥន្ធនៈនិងប្រេងរំអិល, លើចំណាយបេសកកម្មក្នុងប្រទេស និងចំណាយបេសកកម្មក្រៅប្រទេស របស់ក្រសួង ស្ថាប័ន ថ្នាក់កណ្តាល។ ដូចនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវបន្តពិនិត្យកាត់បន្ថយជាអតិបរមានូវការធ្វើដំណើរឆ្ងាយក្នុងការរៀបចំសិក្ខាសាលា និងកិច្ចប្រជុំ នានាជាលក្ខណៈរូបវន្តដោយលើកទឹកចិត្តឱ្យធ្វើតាមប្រព័ន្ធអនឡាញជំនួសវិញ លើកលែងតែករណីចាំបាច់ ប៉ុណ្ណោះ។ ចំពោះការចូលរួមកិច្ចប្រជុំនានានៅក្រៅប្រទេស, ស្នើក្រសួង ស្ថាប័ន ផ្អាកការចូលរួមក្នុងកិច្ចប្រជុំដែល ពុំសូវចាំបាច់, ហើយក្នុងករណីចាំបាច់ខានមិនបាន ដែលតម្រូវឱ្យមានតំណាងរបស់កម្ពុជាចូលរួមប្រជុំ, ក្រសួង ស្ថាប័ន គប្បីស្នើសុំទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចាត់តំណាងស្ថានទូតប្រចាំ នៅប្រទេសម្ចាស់ផ្ទះ ចូលរួមកិច្ចប្រជុំនោះ ជំនួសវិញ។ ក្នុងន័យនេះ, ចំពោះការចូលរួមកិច្ចប្រជុំជាលក្ខណៈរូបវន្តនៅក្រៅប្រទេស ស្នើក្រសួងស្ថាប័ន ជ្រើសរើសតែកិច្ចប្រជុំដែលមានលក្ខណៈយុទ្ធសាស្ត្រ និងចាំបាច់ខ្លាំងបំផុតប៉ុណ្ណោះ។

**ផ្អែកលើមូលដ្ឋានខាងលើនេះ**, *គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវកាត់ចេញនូវមុខសញ្ញាចំណាយដែលបានបញ្ចប់ ឬដែលមិនចាំបាច់ និងមិនសូវចាំបាច់ ដើម្បីសន្សំថវិកាសម្រាប់មុខសញ្ញាចំណាយថ្មី ឬសកម្មភាពថ្មីដែលចាំបាច់ ឬដែលបម្រើឱ្យសកម្មភាពថ្មីៗនៃ*

*កម្មវិធីកែទម្រង់គន្លឹះៗ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។* ដូចនេះ, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោង និងគណនាតម្រូវការចំណាយនៃជំពូកនីមួយៗ តាមគោលការណ៍ ដូចខាងក្រោម៖

- ***ចំណាយជាប្រចាំ*** គឺជាចំណាយដែលមានតម្រូវការជារៀងរាល់ឆ្នាំ រួមមាន៖ ចំណាយលើសម្ភារៈផ្គត់ផ្គង់ និងការថែទាំជាប្រចាំ (ដូចជា៖ សម្ភារៈ ក៏ដូចជាសេវាថែទាំតូចតាច សម្រាប់បម្រើទៅដល់ការថែទាំ និងជួសជុលអគារ, ប្រាសាទ, ផ្លូវថ្នល់, ស្ពាន, លូ, ប្រព័ន្ធធារាសាស្ត្រ, រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ), និងសម្ភារៈផ្គត់ផ្គង់រដ្ឋបាល (ដូចជា៖ សម្ភារៈការិយាល័យ, ការបោះពុម្ព, ការទិញឯកសារ, សម្ភារៈបរិក្ខារប្រើប្រាស់ជាប្រចាំ, ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង ស្ថាប័នត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ យ៉ាងណាមិញ, **ប្រភេទចំណាយនេះ ត្រូវកំណត់ឱ្យបានត្រឹមត្រូវ និងបង្កើតមូលដ្ឋានគណនាតម្រូវការឱ្យបានច្បាស់លាស់ ស្របតាមតម្រូវការជាក់ស្តែង ព្រមទាំងត្រូវវិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដែលអនុវត្តផ្ទាល់។** មុខចំណាយប្រភេទនេះ ក៏ត្រូវគ្រោងដោយឈរលើគោលការណ៍សន្សំសំចៃ និងភាពចាំបាច់ផងដែរ។

- ***ចំណាយមិនប្រចាំ*** គឺជាចំណាយដែលមិនកើតឡើងជារៀងរាល់ឆ្នាំ រួមមាន៖ ចំណាយលើការទិញឧបករណ៍, សម្ភារដឹកជញ្ជូន, សម្ភារៈបរិក្ខារបច្ចេកទេស, គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ធំៗផ្សេងទៀត ក៏ដូចជាគម្រោង ឬសកម្មភាពការងារថ្មី ដែលត្រូវអនុវត្ត និងត្រូវបញ្ចប់វិញក្នុងពេល ១ ឆ្នាំ ព្រមទាំងចំណាយសម្រាប់ការងារជួសជុល, បោះពុម្ព, ការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលា និងបេសកកម្មមួយចំនួន ដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ សម្រាប់ប្រភេទចំណាយនេះ គឺត្រូវគ្រោងដោយមានមូលដ្ឋានគណនាច្បាស់លាស់ អំពីតម្រូវការ រយៈពេលអនុវត្ត និងប្រសិទ្ធភាពនៃការប្រើប្រាស់ សម្រាប់ទាំងរយៈពេលខ្លី និងរយៈពេលមធ្យម។

- ក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្ដាល៖ ត្រូវគ្រោងថវិកាទៅតាមពិតានចំណាយគោលឆ្នាំ ២០២៧ ប៉ុន្តែ ***កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ នឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ***។ ដូចនេះ, រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមាន៖ ការសិក្សា, ការវិភាគ, ការវាយតម្លៃ និងការផ្តល់អំណះអំណាងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។ ក្នុងន័យនេះ, គម្រោងចំណាយដែលមានឯកសារគាំទ្រគ្រប់គ្រាន់ ទើបអាចអនុញ្ញាតឱ្យដាក់ជាកម្មវត្ថុនៃការពិភាក្សា ទាំងនៅក្នុងកិច្ចប្រជុំពិភាក្សាថវិកាកម្រិតបច្ចេកទេស និងកិច្ចប្រជុំពិភាក្សាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។ នេះ គឺមានន័យថា ពិតានចំណាយគោល គឺនៅតែជាកម្មវត្ថុសម្រាប់ការពិភាក្សាការពារគម្រោងថវិកា ដើម្បីបង្កើនសក្តិសិទ្ធិភាពនៃការវិភាជថវិកា ក៏ដូចជាដើម្បីសន្សំសំចៃថវិកាសម្រាប់បំពេញតម្រូវការចំណាយចាំបាច់ថ្មីៗ។

- **មន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើ កញ្ចប់ពិតានចំណាយគោលរួម ដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី ខេត្ត, សម្រាប់ឆ្នាំ ២០២៧ មន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវគ្រោងថវិកាចំណាយយ៉ាងច្រើនបំផុតស្មើនឹងកម្រិតអតិបរមានៃកញ្ចប់ពិតានចំណាយគោល។ ក៏ប៉ុន្តែ ***កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ*** នឹងមិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី ខេត្ត និងរដ្ឋបាលរាជធានីខេត្តពាក់ព័ន្ធ ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់

និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក, សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ, ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមបទបញ្ញត្តិជាធរមាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច, ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡានៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

- គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិនៃក្រសួង ស្ថាប័ននីមួយៗ ត្រូវបានផ្តល់ពិតានចំណាយគោលសម្រាប់ឧបត្ថម្ភធន ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទាល់របស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីៗដែលចាំបាច់។

- ចំពោះការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ ២០២៥ កន្លងមក និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០២៦ នេះ និងផ្អែកលើថ្លៃឯកតាជាក់ស្តែង ហើយចៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ, ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ជាពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារៈបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការបោះពុម្ពប្រណិត សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធិកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជាសេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ, *ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិព័រណ៍*។ កិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន, ចំពោះកិច្ចប្រជុំដែលមិនចំវេនគឺត្រូវសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលជាមុនសិន។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលាដែលគ្រោងក្នុងថវិកា ត្រូវបង្ហាញពីភាពចាំបាច់ និងភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តក្នុងឆ្នាំ ២០២៦ ហើយលែងត្រូវការក្នុងឆ្នាំ ២០២៧ ឬសកម្មភាពការងារដែលនឹងត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៦។ លើសពីនេះ, ត្រូវកាត់ចេញនូវទំហំចំណាយនៃសកម្មភាពការងារមួយចំនួនដែលត្រូវបានវាយតម្លៃថា លែងមានសារៈសំខាន់។ ក្នុងន័យនេះ, ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ ដែលត្រូវអនុវត្ត និងដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងមានយុត្តការណ៍អំពីភាពចាំបាច់ និងបន្ទាន់ ព្រមទាំងមានការពន្យល់ និងផ្តល់អំណះអំណាងច្បាស់លាស់ និងត្រឹមត្រូវ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិត ច្បាស់លាស់ ទើបចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។

- ចំពោះតម្រូវការចំណាយបន្ថែម លើសពីកញ្ចប់ពិតានចំណាយគោលដែលផ្តល់ជូនក្រសួង ស្ថាប័ននីមួយៗ គឺត្រូវឆ្លងការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងពិនិត្យសម្រេចនៅក្នុងការពិភាក្សាថវិកាកម្រិតថ្នាក់



ℊ

ដឹកនាំ, ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងស្នើសុំការសម្រេច ឬ ស្នើសុំការសម្រេចឡើងវិញពីរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តិការណ៍ស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។

*- សម្រាប់ក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានភារកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែម សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការរឹតត្បិត ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលពិភាក្សាការពារគម្រោងថវិកាប្រចាំឆ្នាំ។*

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយជាប្រចាំសម្រាប់កិច្ចដំណើរការរដ្ឋបាល និងសោហ៊ុយបេសកកម្មក្នុងប្រទេស និងក្រៅប្រទេស ជាដើម ទៅតាមអង្គភាពថវិកា ឱ្យបានច្រើនក្នុងកម្រិតអតិបរមា។

- ដើម្បីអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ, ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាផែនការសកម្មភាពការងារទៅតាមកម្មវិធី និងស្នើសុំថវិកាក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិការួមប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ។ ទន្ទឹមនេះ, ក្រសួង ស្ថាប័ននីមួយៗ ត្រូវគិតគូរពិចារណាដាក់បញ្ចូលទៅក្នុងគម្រោងថវិកានូវបណ្តាអាទិភាពបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដូចមានចែងក្នុងផែនការស្តីពីការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (២០២០) និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យ និងវិភាជថវិកាជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋាននៃភាពចាំបាច់ និងសក្តិសិទ្ធិភាព ព្រមទាំងស្របតាមលទ្ធភាពថវិកាជាក់ស្តែង។

- ក្រសួង ស្ថាប័នត្រូវពិនិត្យលទ្ធភាពក្នុងការផ្ទេរធនធានថវិកាពីកម្មវិធីមួយ ទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយ ទៅអង្គភាពថវិកាមួយទៀត នៅផ្ទៃក្នុងក្រសួង ស្ថាប័ននីមួយៗឱ្យអស់លទ្ធភាព ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធានរវាងអង្គភាពថវិកានីមួយៗ ក្នុងក្របខ័ណ្ឌនៃកញ្ចប់ពិតានចំណាយគោលរបស់ខ្លួន និងត្រូវចៀសវាងការបំប៉ោងចំណាយ ដោយមូលហេតុនៃការអនុវត្តថវិកាសមិទ្ធកម្ម។

- ជាមួយគ្នានេះ ដើម្បីបង្កើនសក្តិសិទ្ធិភាពចំណាយនៅដំណាក់កាលរៀបចំ និងពិភាក្សាការពារគម្រោងថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវប្រភេទចំណាយមិនប្រចាំដែលជាថវិកាផ្ទៃក្នុងក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)។ ទំហំថវិកាដែលនៅសល់ក្នុងក្របខ័ណ្ឌពិតាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធី បម្រើឱ្យគោលនយោបាយថ្មី នៅក្នុងក្រសួង ស្ថាប័នដដែល ឬទៅក្រសួង ស្ថាប័នមួយផ្សេងទៀត។

គ-ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក ២១) និងចំណាយជួសជុលនិងថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១) ត្រូវបន្តអនុវត្តតាមនីតិវិធីដែលបាននិងកំពុងអនុវត្តជាធរមាន និង តាមគោលការណ៍ ដូចខាងក្រោម៖

- ក្នុងចំណោមក្រសួងទាំង ១១ ដែលនឹងទទួលបានការវិភាជថវិកាក្នុងច្បាប់ហិរញ្ញវត្ថុផ្ទាល់, មានក្រសួងចំនួន ៩ រួមមាន៖ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងមហាផ្ទៃ,

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធីនិងអនុកម្មវិធី។ ក្នុងន័យនេះ ក្រសួងទាំង ៩ នេះ ត្រូវរៀបចំបញ្ជីគម្រោងអាទិភាពប្រចាំឆ្នាំឱ្យបានទាន់ពេល ដើម្បីស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលជាមុន សម្រាប់ជាមូលដ្ឋាននៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ដោយឡែក ក្រសួង ២ ទៀត រួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក៏ត្រូវបន្តសាកល្បងធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្ត នៅកម្រិតកម្មវិធីនិងអនុកម្មវិធីផងដែរ។ ចំពោះការកំណត់អាទិភាព និងជ្រើសរើសគម្រោងដែលក្រសួងនីមួយៗបានស្នើឡើង គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការ គណៈកម្មការ ឬក្រុមការងារអន្តរក្រសួងដោយផ្អែកទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍កំណត់អាទិភាពគម្រោងដែលមានចែងនៅក្នុងសារាចរនេះសម្រាប់ជាមូលដ្ឋានស្នើសុំការពិនិត្យនិងសម្រេចពីរាជរដ្ឋាភិបាល។

- សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីទទួលបានថវិកាពីកញ្ចប់ថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ត្រូវសិក្សានិងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងរៀបចំអាទិភាវូបនីយកម្មគម្រោង គោរពស្នើសុំការសម្រេចរបស់រាជរដ្ឋាភិបាល តាមលទ្ធភាពថវិកាប្រចាំឆ្នាំ។ គម្រោងវិនិយោគដែលអាចស្នើឡើង ដើម្បីពិភាក្សា ត្រូវបំពេញតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

- ការគ្រោងចំណាយសម្រាប់គម្រោងវិនិយោគសាធារណៈ និងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ផ្លូវថ្នល់ និងធារាសាស្ត្រ)ត្រូវបន្តអនុវត្តតាមគោលការណ៍កំណត់អាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- <u>**វិស័យផ្លូវថ្នល់**</u>
  - ✓ **អាទិភាពទី ១៖** គម្រោងថែទាំ ជួសជុល ស្តារ និងលើកកម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ តាមសមត្ថកិច្ចទទួលខុសត្រូវរៀងៗខ្លួន និងផ្អែកតាមចំណាត់ថ្នាក់នៃមាតិកាថវិកាដើម្បីថែរក្សាសមិទ្ធផលឱ្យមានចីរភាព ធានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។
  - ✓ **អាទិភាពទី ២៖** គម្រោងថ្មីដែលមានការសម្រេចពី ប្រមុខរាជរដ្ឋាភិបាល។
  - ✓ **អាទិភាពទី ៣៖** គម្រោងពហុឆ្នាំដែលត្រូវសាងសង់បន្ត ឬបញ្ចប់។ ក្នុងករណីចាំបាច់ត្រូវពិនិត្យ វាយតម្លៃឡើងវិញនូវប្រសិទ្ធភាព និងអត្ថប្រយោជន៍នៃគម្រោង។
  - ✓ **អាទិភាពទី ៤៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយ។
- <u>**វិស័យធារាសាស្ត្រ**</u>
  - ✓ **អាទិភាពទី ១៖** គម្រោងថែទាំ ជួសជុល ស្តារ និងលើកកម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដើម្បីថែរក្សាសមិទ្ធផលឱ្យមានចីរភាព, ធានាបាននូវប្រសិទ្ធភាព ក្នុងការប្រើប្រាស់ និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។
  - ✓ **អាទិភាពទី ២៖** គម្រោងពហុឆ្នាំដែលត្រូវសាងសង់បន្ត ឬបញ្ចប់ ដើម្បីបង្កប់ប្រសិទ្ធភាពសេដ្ឋកិច្ច សង្គម។

- ✓ អាទិភាពទី ៣៖ គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ និងមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយ។
- <u>វិស័យអប់រំ</u>
  - ✓ អាទិភាពទី ១៖ គម្រោងដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាល។
  - ✓ អាទិភាពទី ២៖ គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំ ដែលគាំទ្រដល់ការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល ក៏ដូចជាការកែលម្អការលើកកម្ពស់វិស័យអប់រំជាពិសេស ការសាងសង់អគារសិក្សា ដោយឈរលើមូលដ្ឋាននៃការសិក្សា និងវាយតម្លៃច្បាស់លាស់អំពីតម្រូវការជាអាទិភាព។
- <u>វិស័យសុខាភិបាល</u>
  - ✓ អាទិភាពទី ១៖ គម្រោងជួសជុល សាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល និងបរិក្ខារពេទ្យ ដើម្បីថែរក្សាសមិទ្ធផលឱ្យមានចីរភាព និងជានាប្រសិទ្ធភាពក្នុងការប្រើប្រាស់។
  - ✓ អាទិភាពទី ២៖ គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ជាពិសេសការសាងសង់មន្ទីរពេទ្យ, មណ្ឌលសុខភាព និងការបំពាក់បរិក្ខារពេទ្យតាមមូលដ្ឋានសុខាភិបាល សំដៅគាំទ្រការអនុវត្តផែនការគន្លឹះរបស់រាជរដ្ឋាភិបាល ក៏ដូចជាការកែលម្អការលើកកម្ពស់វិស័យសុខាភិបាល ដោយឈរលើមូលដ្ឋាននៃការសិក្សា និងវាយតម្លៃច្បាស់លាស់អំពីតម្រូវការជាអាទិភាព។
- <u>វិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ</u>
  - ✓ អាទិភាពទី ១៖ គម្រោងស្ថាបនាប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់។
  - ✓ អាទិភាពទី ២៖ គម្រោងជួសជុលនិងស្ថាបនាពន្ធនាគារ។
  - ✓ អាទិភាពទី ៣៖ គម្រោងគាំទ្រនានាលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈតាមការចាំបាច់។
- <u>វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ</u>
  - ✓ អាទិភាពទី ១៖ គម្រោងជួសជុល ស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសដើម្បីជានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ ការគាំទ្រតម្រូវការទីផ្សារការងារ និងលើកកម្ពស់ផលិតកម្ម។
  - ✓ អាទិភាពទី ២៖ គម្រោងបំពាក់ឧបករណ៍ និងសម្ភារៈបច្ចេកទេសចាំបាច់លើវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ។
- <u>វិស័យទឹកស្អាត៖</u>
  - ✓ អាទិភាពទី ១៖ គម្រោងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបណ្តាញចែកចាយទឹកស្អាត។
  - ✓ អាទិភាពទី ២៖ គម្រោងបំពាក់ឧបករណ៍ពិសោធន៍ និងសម្ភារៈបច្ចេកទេស។

ឃ-ចំណាយមូលធនវិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍ៖ ក្រសួង ស្ថាប័នចំនួន ១១ ដែលនឹងទទួលបាននូវការវិភាជថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) ព្រមទាំងក្រសួង ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ឬគ្រោងនឹងទទួលបាន



ꝗ

ហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៧-២០២៩) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

៣០-ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ៖ ក្នុងគោលបំណងលើកកម្ពស់គុណភាព និងអនុលោមភាពនៃការរៀបចំ និងការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំ ក៏ដូចជាដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព ជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែ មករា នៃឆ្នាំសារពើពន្ធ គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០២៧ របស់ខ្លួនចំនួនពីរច្បាប់ (១ ច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និង ១ ច្បាប់ទៀតបញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សម្រាប់ការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងការពិភាក្សាការពារគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្ដីពីការរៀបចំផែនការលទ្ធកម្ម។

បន្ទាប់មក, ផ្អែកលើស្មារតី និងលទ្ធផលនៃកិច្ចប្រជុំការពារគម្រោងថវិកា, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវកែសម្រួលសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយនឹងកញ្ចប់ថវិកាដែលទទួលបាននៅក្នុងកិច្ចប្រជុំការពារគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី ៣ ខែ វិច្ឆិកា ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា។

៣១-ការរៀបចំផែនការរដ្ឋទេយ្យបុរេប្រទាន៖ ត្រូវធ្វើឡើងដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ សម្រាប់ពិនិត្យនិងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។ ក្នុងអំឡុងពេលប្រជុំការពារគម្រោងថវិកា មិនតម្រូវឱ្យពិនិត្យមើលលម្អិតលើតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានទេ ប៉ុន្តែក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវធានាថាមុខចំណាយថវិកាដែលត្រូវយកមករៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន មិនត្រូវត្រួតគ្នានឹងមុខចំណាយថវិកាដែលត្រូវបានគ្រោងទុកសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ, តាមនីតិវិធីទូទាត់ត្រង់ និង តាមនីតិវិធីចំណាយផ្សេងទៀតទេ។

៣២-ការផ្ដល់របាយការណ៍សមិទ្ធកម្ម៖ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលអនុវត្តថវិកាសមិទ្ធកម្ម ត្រូវផ្ដល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាឆ្នាំ ២០២៥ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយ

ក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬការកាត់បន្ថយគម្រោងចំណាយឆ្នាំ ២០២៧ ផងដែរ។ *នៅពេលពិភាក្សាការពារគម្រោងថវិកា, ក្រសួង ស្ថាប័ននីមួយៗត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ ២០២៥ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ ២០២៦ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ ២០២៧។*

៣៣-ទន្ទឹមនេះ, ក្នុងគោលដៅដើម្បីធានាបាននូវការអនុវត្តជាមូលដ្ឋាននូវថវិកាសមិទ្ធកម្មនៅឆ្នាំ ២០២៧, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើការពិភាក្សាការពារគម្រោងថវិកា ដោយផ្តោតលើ**អភិក្រមចម្រុះ ដែលបំពេញគ្នាទៅវិញទៅមក និងមានលក្ខណៈទន់ភ្លន់ គឺ៖ តាមរចនាសម្ព័ន្ធកម្មវិធី រួមមាន តាមកម្មវិធី អនុកម្មវិធី និងតាមសកម្មភាពការងារ** ឬទៅតាមមុខសញ្ញាចំណាយ អាស្រ័យលើកត្តាជាក់ស្តែងនៃរចនាសម្ព័ន្ធថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័ននីមួយៗ។ អភិក្រមថ្មីនេះ នឹងជួយកាត់បន្ថយបានជាអតិបរមានូវការការពារគម្រោងថវិកាផ្អែកលើធាតុចូល (Input) ដោយតម្រង់ការពិភាក្សាថវិកាដោយផ្អែកលើសកម្មភាព (Activity) និងធាតុចេញ (Output) ជាសំខាន់វិញ។ ទោះជាយ៉ាងនេះក្តី, ការពិភាក្សាការពារគម្រោងថវិកាដោយផ្អែកលើធាតុចូល ក៏នៅតែត្រូវបានគិតគូរលើមុខចំណាយមួយចំនួននៃក្រសួង ស្ថាប័នខ្លះ ដែលត្រូវបានអនុញ្ញាតឱ្យរៀបចំថវិកាសមិទ្ធកម្មតាមទម្រង់មានលក្ខណៈស្រាល ជាពិសេស ក្រសួង ស្ថាប័ន ស្ថិតក្នុងវិស័យរដ្ឋបាលទូទៅ និងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

**៣៤-ការបម្រែបម្រួលនៃការគ្រោងថវិកាតាមកម្មវិធី៖** ផ្អែកលើមូលដ្ឋាននៃច្បាប់ថវិកាឆ្នាំ ២០២៦ ដែលកំពុងអនុវត្ត, ក្នុងការរៀបចំថវិកាឆ្នាំ ២០២៧, ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្តដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀតផ្ទៃក្នុង ឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យឥណទានដើមឆ្នាំរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

៣៥-អនុវត្តតាមប្រកាសលេខ ៣៥៤ សហវ.ប្រក ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០២២ **ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិការគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង**, នៅឆ្នាំ ២០២៦ នេះ, ក្រសួង ស្ថាប័ន ចំនួន ២៤ រួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ), ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធម្មការ និងសាសនា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកិច្ចការនារី, ក្រសួងរ៉ែ និងថាមពល, ក្រសួងទេសចរណ៍, ក្រសួងអភិវឌ្ឍន៍ជនបទ, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងការពារជាតិ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ក្រុមប្រឹក្សាធម្មនុញ្ញ, ក្រសួងព័ត៌មាន, ក្រសួងពាណិជ្ជកម្ម, ក្រសួងបរិស្ថាន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, អាជ្ញាធរសេវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ និងរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

ត្រូវបានជ្រើសរើសឱ្យអនុវត្តសាកល្បងនូវគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង។ សម្រាប់ការគ្រោងថវិកាឆ្នាំ ២០២៧, ក្រសួង ស្ថាប័ន ដែលនៅសេសសល់ ត្រូវបានជ្រើសរើសបន្ថែមសម្រាប់ការអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង ដោយតម្រូវឱ្យផ្លាស់ប្តូរការគ្រោងថវិការបស់ខ្លួនលើមុខចំណាយជាសារវន្តមួយចំនួន (ឧ. ចំណាយទិញរថយន្ត និងចំណាយទិញទោចក្រយានយន្ត) ដែលមានចរិតជាចំណាយមូលធន ដោយប្តូរពីការគ្រោងក្នុងជំពូក ៦០ និងជំពូក ៦១ នៃថវិកាចំណាយចរន្ត ទៅគ្រោងក្នុងជំពូក ២០, ជំពូក ២១ ឬជំពូក ២៣ នៃចំណាយមូលធនវិញ ស្របតាមវិធីសាស្ត្រដែលមានចែងលម្អិតក្នុងគោលការណ៍ណែនាំនេះ។

៣៦-ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលនៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ។

## ៤.៣-កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៧

៣៧-រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលនូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧។ ក្នុងកិច្ចដំណើរការនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាលត្រូវដឹកនាំការរៀបចំ ដើម្បីធានាឱ្យសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៧ និងសំណុំឯកសារពាក់ព័ន្ធ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដោយព្រះរាជក្រម ឱ្យបានចប់សព្វគ្រប់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ស្របតាមមាត្រា ៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣។ ដូចនេះ, **ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងគម្រោងចំណូល ចំណាយថវិកាឆ្នាំ ២០២៧** ដែលក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវដាក់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **គឺជាឯកសារចាំបាច់មិនអាចខ្វះបានសម្រាប់ការពិភាក្សាការពារគម្រោងថវិកាទាំងកម្រិតបច្ចេកទេស និងការពិភាក្សាការពារគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។**

ក្នុងន័យនេះ, ក្នុងករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធណាមួយមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោល-ការណ៍ និងតារាងគំរូ ដែលភ្ជាប់ជាមួយសារាចរនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះឱ្យបានទាន់ពេល ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋានត្រឹមកម្រិតពិតានចំណាយគោល ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧ ឱ្យបានទាន់ពេល និងគ្រប់ជ្រុងជ្រោយ។**

**៥-សេចក្ដីសន្និដ្ឋាន**

៣៨-សារាចរនេះ ត្រូវបានរៀបចំឡើង ដោយផ្អែកលើគោលបំណងចម្បង ដែលត្រូវបានកំណត់ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ ពោលគឺ *«ដើម្បីការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី រក្សាលំនឹងជីវភាពប្រជាជននិងជំរុញសន្ទុះកំណើនរយៈពេលមធ្យម ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្ពស់ដោយធានានូវលទ្ធភាពឆ្លើយតបគ្រប់គ្រាន់ និងចីរភាពហិរញ្ញវត្ថុសាធារណៈ»*។ ទន្ទឹមនេះ, ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៧-២០២៩ ក៏បានផ្ដល់នូវទស្សនវិស័យអំពីនិន្នាការចំណូល និងចំណាយថវិកាជាតិ ព្រមទាំងកំណត់លម្ហថវិកាដែលសម្រាប់រាជរដ្ឋាភិបាលមានលទ្ធភាពដោះស្រាយ តម្រូវការចំណាយជាយុទ្ធសាស្ត្រ និងជាអាទិភាពសម្រាប់រយៈពេលខ្លី និងមធ្យម ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្ពស់ពីកត្តាខាងក្រៅ ជាពិសេសពីកម្មវិបាកនៃការអនុវត្តគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក បញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ និងសង្គ្រាមនៅមជ្ឈិមបូព៌ាដែលបណ្ដាលឱ្យមានវិបត្តិថាមពល។ សំខាន់ជាងនេះទៀត, ការផ្ដល់ពិតានចំណាយគោលសម្រាប់គ្រប់ក្រសួង ស្ថាប័ន និងពិតានចំណាយគោលសម្រាប់ឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ បានផ្ដល់ជាព័ត៌មានដល់គ្រប់ក្រសួង ស្ថាប័ន អំពីភាពអាចប៉ាន់ប្រមាណបាននៃធនធានថវិកាដែលអាចទទួលបាន, សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៧-២០២៩ និងការរៀបចំគម្រោងថវិកាឆ្នាំ ២០២៧ ព្រមជាមួយនឹងការផ្ដល់នូវការណែនាំអំពីគោលការណ៍ និងបច្ចេកទេសនៃការគ្រោងចំណូល និងចំណាយ ជាពិសេសផ្ដល់លទ្ធភាពដល់គ្រប់ក្រសួង ស្ថាប័ន អាចធ្វើអាទិភាវូបនីយកម្មមុខចំណាយ និងធ្វើវិចារណកម្មចំណាយជាមួយនឹងធនធានដែលមាន ដោយបន្តចាត់ទុកការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ជាអាទិភាពសំខាន់បំផុត ព្រមទាំងតម្រង់ធនធានថវិកាសម្រាប់ការរក្សាលំនឹងជីវភាពប្រជាជន, ជំរុញជវភាពនៃកំណើនសេដ្ឋកិច្ច និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រឈមនឹងហានិភ័យដែលនឹងកើតឡើងក្នុងពេលខាងមុខជាយថាហេតុ។ សំខាន់ជាងនេះទៅទៀត, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល នឹងបន្តតាមដានដោយយកចិត្តទុកដាក់លើការវិវឌ្ឍ និងវាយតម្លៃសភាពការណ៍ឡើងវិញ មុនពេលរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៧ ដើម្បីកែសម្រួលក្របខ័ណ្ឌនេះតាមការចាំបាច់ និងតាមការណ៍ជាក់ស្ដែង ជាពិសេសក្នុងកាលៈទេសៈដែលសភាពការណ៍មិនអំណោយផល។

៣៩-ទោះជាយ៉ាងណាក្ដី, ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្ដូរផ្ដាច់ ជាពិសេសត្រូវតែផ្លាស់ប្ដូរឥរិយាបថ និងផ្នត់គំនិតក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខ័ណ្ឌ គោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរនេះ។ ទន្ទឹមនេះ, គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យការគ្រប់គ្រងនិងប្រើប្រាស់ថវិកា ដើម្បីបង្កើនសក្ដានុពលនៃតួនាទីរបស់ថវិកា មិនត្រឹមតែជាឧបករណ៍គោលនយោបាយ ដែលមានប្រសិទ្ធភាពខ្ពស់របស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងធ្វើជាចន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀតផងដែរ។

៤០-ពេលទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំជាការប្រញាប់នូវ *ផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២៧-២០២៩ ដែលមានវិសាលភាពគ្របដណ្ដប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញ*

*រាជធានី ខេត្ត, គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ), និងរៀបចំគម្រោងចំណូល ចំណាយឆ្នាំ ២០២៧* និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ចំនួនពីរច្បាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២៦ ជាកំហិត ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលគ្រប់គ្រាន់ធ្វើការបូកសរុបសម្រាប់ជាមូលដ្ឋាននៃការវិភាជថវិកាផ្អែកតាមលទ្ធភាពថវិកា និងសម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេសចាប់ពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២៦ និងការពិភាក្សាថវិកាកម្រិតថ្នាក់ដឹកនាំជាមួយគ្រប់ក្រសួង ស្ថាប័ន ចាប់ពីថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០២៦។ ក្នុងការអនុវត្តសារាចរនេះ, ប្រសិនបើក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា)។

៤១-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ និងមន្ទីរជំនាញ រាជធានី ខេត្ត ព្រមទាំងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៤រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
- គ្រប់គណៈអភិបាលក្រុង ស្រុក
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ